ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

## បូកសរុបលទ្ធផលការងារ ៥ឆ្នាំ ២០១៧-២០២១
## នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤

រៀបចំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធ និងយុវនីតិសម្បទា

# មាតិកា

**បញ្ជីតារាង** ........ 3

I-**លទ្ធផលការងារ និងបញ្ហាប្រឈម** ........ 4

កម្មវិធីទី១៖ ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម ........ 4

អភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះ និងងាយរងគ្រោះ និងកិច្ចការគ្រួសារ ........ 4

អភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា ........ 7

អភិវឌ្ឍសុខុមាលភាពជនពិការ ........ 10

អភិវឌ្ឍសុខុមាលភាពមនុស្សចាស់ ........ 12

អភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន ........ 13

កម្មវិធីទី២៖ បង្កើនប្រសិទ្ធភាពប្រព័ន្ធសន្តិសុខសង្គម និងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយ ........ 13

សម្បទាជនពិការ ........ 13

អភិវឌ្ឍសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលប្រកបដោយប្រសិទ្ធភាព ........ 13

បង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងគ្រួសារ ........ 15

បន្តនិរន្តរភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ ........ 16

កម្មវិធីទី៣៖ ពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍភាពជាដៃគូ ........ 16

ពង្រឹងសមត្ថភាពស្ថាប័ន និងភាពជាដៃគូ ........ 16

អភិវឌ្ឍធនធានមនុស្ស ........ 18

II-**ទិសដៅការងារគោលនយោបាយ** ........ 20

កម្មវិធីទី១៖ ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គមការអភិវឌ្ឍសុខុមាលភាពជនរងគ្រោះនិងជនងាយរងគ្រោះ និងកិច្ចការគ្រួសារ ........ 20

ការអភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា ........ 20

ការអភិវឌ្ឍសុខុមាលភាពជនពិការ ........ 21

អភិវឌ្ឍសុខុមាលភាពមនុស្សចាស់ ........ 22

ការអភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន ........ 22

កម្មវិធីទី២៖ បង្កើនប្រសិទ្ធភាពប្រព័ន្ធសន្តិសុខសង្គម និងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ ........ 22

អភិវឌ្ឍសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលប្រកបដោយប្រសិទ្ធភាព ......... 22
ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងគ្រួសារ ............ 22
ការបន្តនិរន្តរភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ................................ 23
កម្មវិធីទី៣៖ ពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍភាពជាដៃគូ........................................ 23
ពង្រឹងសមត្ថភាពស្ថាប័ន និងភាពជាដៃគូ ........................................................ 23
ការអភិវឌ្ឍធនធានមនុស្ស ........................................................................ 24
**គោលដៅចំណុចនៃសូចនាករសំខាន់ៗ** .............................................................. 25

# បញ្ជីតារាង


តារាងទី១.លទ្ធផលសម្រេចបានអនុកម្មវិធីទី១.១ ........ 6
តារាងទី២.លទ្ធផលសម្រេចបានអនុកម្មវិធីទី១.២ ........ 10
តារាងទី៣.លទ្ធផលសម្រេចបានអនុកម្មវិធីទី១.៣ ........ 12
តារាងទី៤.លទ្ធផលសម្រេចបានអនុកម្មវិធីទី១.៤ ........ 13
តារាងទី៥.លទ្ធផលសម្រេចបានអនុកម្មវិធី ២.១ ........ 15
តារាងទី៦.លទ្ធផលសម្រេចបានអនុកម្មវិធី ២.២ ........ 15
តារាងទី៧.លទ្ធផលសម្រេចបានអនុកម្មវិធីទី២.៣ ........ 16
តារាងទី៨.លទ្ធផលសម្រេចបានអនុកម្មវិធី ៣.២ ........ 18

## របាយការណ៍
## បូកសរុបលទ្ធផលការងារ ៥ឆ្នាំ ២០១៧-២០២១
## នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤
## របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ដោយសារការផ្ទុះឡើងនូវជំងឺកូវីដ-១៩ ក្នុងឆ្នាំ២០២០ និងបន្តអូសបន្លាយដល់ឆ្នាំ២០២១ បានបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរបំផុតមកលើសេដ្ឋកិច្ច និងសង្គម នៃបណ្តាប្រទេសស្ទើរតែទាំងអស់នៅលើពិភពលោក រួមទាំងប្រទេសកម្ពុជាយើងផងដែរ។ ធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាថមថយសន្ទុះបាត់បង់កំណើន ដែលក្នុងរយៈពេល ៥ឆ្នាំ ២០១៧-២០២១ កំណើតសេដ្ឋកិច្ចកម្ពុជាគិតជាមធ្យមកើនឡើងប្រមាណ ៤,០៨% ក្នុងមួយឆ្នាំប៉ុណ្ណោះ។

ផ្អែកលើយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ចតុកោណទី១ "ការអភិវឌ្ឍធនធានមនុស្ស" ត្រង់មុំទី៤៖ ការពង្រឹងសមភាពយេនឌ័រ និងកិច្ចគាំពារសង្គម ដើម្បីលើកស្ទួយស្ថានភាពសង្គម សេដ្ឋកិច្ច និងពង្រឹងតួនាទីស្ត្រី បានបង្ហាញយ៉ាងច្បាស់អំពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងនូវបណ្តាញសុវត្ថិភាពសង្គម និងកិច្ចគាំពារសង្គម រួមចំណែកក្នុងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន ជាពិសេស ជនរងគ្រោះ និងងាយរងគ្រោះ ឱ្យរួចផុតពីហានិភ័យទាំងឡាយ។ ក្រសួង ស.អ.យ. បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រ ២០១៩-២០២៣ ផ្តោតលើកម្មវិធីសំខាន់ៗចំនួនបីគឺ១.ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម ២.ការបង្កើនប្រសិទ្ធភាពប្រព័ន្ធសន្តិសុខសង្គមនិងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ និង៣.ការពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍភាពជាដៃគូ និងអនុកម្មវិធីចំនួន ១២ រួមមាន ១.ការអភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះនិងងាយរងគ្រោះ និងកិច្ចការគ្រួសារ ២.ការអភិវឌ្ឍសុខុមាលភាពកុមារនិងយុវនីតិសម្បទា ៣.ការអភិវឌ្ឍសុខុមាលភាពជនពិការ ៤.ការអភិវឌ្ឍសុខុមាលភាពមនុស្សចាស់ ៥.ការអភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន ៦.ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គមរាជធានី ខេត្ត ៧.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ៨.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន ៩.ការបន្តនិរន្តរភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ ១០.ការពង្រឹងសមត្ថភាពស្ថាប័ននិងភាពជាដៃគូ ១១.ការអភិវឌ្ឍធនធានមនុស្ស និង១២.ការពង្រឹងសមត្ថភាពស្ថាប័ននិងអភិវឌ្ឍភាពជាដៃគូរាជធានី ខេត្ត។ ជាអាទិ៍ក្នុងរយៈពេល ៥ឆ្នាំ ២០១៧-២០២១ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាអនុវត្តសម្រេចបានលទ្ធផលដូចខាងក្រោម៖

### I-លទ្ធផលការងារ និងបញ្ហាប្រឈម

### កម្មវិធីទី១៖ ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម

### អភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះ និងងាយរងគ្រោះ និងកិច្ចការគ្រួសារ

- បានអនុវត្តកម្មវិធីសង្គ្រោះបន្ទាន់ ដោយសហការជាមួយកាកបាទក្រហមកម្ពុជា និងអង្គការនានា ផ្តល់ជំនួយសង្គ្រោះបន្ទាន់ ជាស្បៀង និងសម្ភារផ្សេងៗ ដល់ប្រជាជនរងគ្រោះដោយគ្រោះធម្មជាតិ ប្រជាជនរងគ្រោះ និងងាយរងគ្រោះ ប្រជាជនក្រីក្រ ទុគតជន សរុបចំនួន ២៨០ ២៩២គ្រួសារ
- ដើម្បីជួយគាំទ្រផ្នែកជីវភាព និងសុខុមាលភាពរបស់ប្រជាជនក្រីក្រដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលបានប្រកាសដាក់ឱ្យអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ប្រជាជនក្រីក្រនិងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០។ ចាប់ពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ រហូតមកដល់ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ ប្រជាជនក្រីក្រ និងងាយរងគ្រោះដោយសារជំងឺកូវីដ១៩ បានមកចុះឈ្មោះទទួលសេវាសរុបចំនួន ៦៨៤ ៧៧១គ្រួសារ ដែលចំណាយថវិកាសរុបចំនួន ២ ១២៦ ៦៥៧ ៤១៨ ០០០៛ (គ្រួសារក្រីក្រកម្រិត១ ចំនួន ២៥៣ ៧៨៥គ្រួសារ និងគ្រួសារក្រីក្រកម្រិត២ ចំនួន ៤៣០ ៩៨៦គ្រួសារ) ក្នុងនោះ ចំនួនមនុស្សវ័យចាស់អាយុពី៦០ឆ្នាំទទួលបានការបើកសាច់ប្រាក់ក្នុងកំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ចំនួន៣៣៨ ០៧៦នាក់ ចំនួនជនមានពិការភាពទទួលបានការបើកសាច់ប្រាក់ក្នុងកំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ចំនួន ៦២ ១៧៤នាក់ និងចំនួនគ្រួសារផ្ទុកមេរោគអេដស៍ដែលទទួលបានការបើកសាច់ប្រាក់ក្នុងកំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ចំនួន

១ ៩៦៤គ្រួសារ។ មិនតែប៉ុណ្ណោះ រាជរដ្ឋាភិបាលបានបង្កើតកម្មវិធីជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់សម្រាប់ប្រជាពលរដ្ឋនិងគ្រួសារប្រជាពលរដ្ឋដែលមានការលំបាកផ្នែកជីវភាព ប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាព និងគ្រួសារប្រជាពលរដ្ឋដែលមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ ក្នុងព្រឹត្តការណ៍ ២០ កុម្ភៈ ២០២១ ដោយចាប់អនុវត្តពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១។ គិតមកដល់ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ គ្រួសារដែលបានទទួលប្រាក់ឧបត្ថម្ភសរុបចំនួន ១២៩ ៦៦៦ គ្រួសារ ចំណាយថវិកាសរុបចំនួន ៣៤ ៧១៥ ១៨៣ ៦០០៛

- បានប្រកាសដាក់ឱ្យដំណើរការកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ។ បើគិតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ រាជរដ្ឋាភិបាលបានផ្តល់ប្រាក់ឧបត្ថម្ភជូនស្ត្រីមានផ្ទៃពោះ ៨៧ ០១២ នាក់ និងកុមារអាយុក្រោម ២ឆ្នាំ ៤២ ៩៨៨នាក់ ដែលចំណាយថវិកាសរុបចំនួន ៦១ ៧៧៦ ៩៦០ ០០០៛
- បានសង្គ្រោះ អប់រំផ្លូវចិត្ត ពិគ្រោះយោបល់ ថែទាំសុខភាពជូនជនអនាថាសរុបចំនួន ៩ ៤២៧នាក់ ក្រៅពីទទួលបានសេវាខាងលើ ជនអនាថាចំនួន ៥ ១៤០នាក់ បានទទួលសេវាស្តារនីតិសម្បទា បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងការធ្វើសមាហរណកម្មទៅក្នុងសហគមន៍។ បានផ្សព្វផ្សាយ អប់រំ បញ្ជ្រាបការយល់ដឹងស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពដល់អាជ្ញាធរមូលដ្ឋាន និងប្រជាជន ៥៨១នាក់
- មជ្ឈមណ្ឌលជនវិបល្លាសស្មារតីស្ថិតនៅភូមិបាគូ ឃុំបាគូ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាលត្រូវបានបង្កើតឡើង និងសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩ ក្រោមអធិបតីភាពសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ មជ្ឈមណ្ឌលនេះបានទទួលជនវិបល្លាសស្មារតីឱ្យស្នាក់នៅចំនួន ៦៨នាក់ និងបានសមាហរណកម្មទៅសហគមន៍វិញចំនួន ៧នាក់
- បានផ្តល់សេវាថែទាំ និងគាំទ្រនៅសហគមន៍ដល់ជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗបានចំនួន ៩ ២៦៥នាក់ ក្នុងនោះ មានការអប់រំផ្សព្វផ្សាយ វគ្គបំណិនជីវិត អប់រំសុខភាព សេវាប្រឹក្សាយោបល់ និងការបង្កើតមុខរបរខ្នាតតូចដល់គ្រួសារ និងកុមារដែលរងផលប៉ះពាល់ដោយសារជំងឺអេដស៍
- បានបង្កើត និងអនុវត្តកម្មវិធី ស្តីពីការអភិវឌ្ឍគ្រួសារ បំផុសលើកទឹកចិត្តការកសាងគ្រួសារល្អ ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ តាមរយៈការរៀបចំទិវាជាតិ និងអន្តរជាតិ ស្តីពីគ្រួសារ ១៥ឧសភា ជារៀងរាល់ឆ្នាំ និងចុះផ្សព្វផ្សាយទិវាអន្តរជាតិស្តីពីគ្រួសារ ១៥ ឧសភា ដល់សិស្សនិស្សិតនៅតាមវិទ្យាល័យ និងសាកលវិទ្យាល័យផងដែរ។ បានបញ្ជ្រាបការងារយេនឌ័រទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ លើកកម្ពស់តួនាទីស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត តាមរយៈការផ្សព្វផ្សាយទស្សនទានយេនឌ័រ និងអនុសញ្ញា ស៊ី-ដ (CEDAW) ដល់មន្ត្រីបង្គោលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការផ្សព្វផ្សាយការយល់ដឹង ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារដល់សហគមន៍
- បានផ្សព្វផ្សាយស្តីពីការអប់រំសីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរផ្សារភ្ជាប់នឹងទិវានៃក្តីស្រលាញ់ នៅតាមសាលាបឋមសិក្សា វិទ្យាល័យ និងសាកលវិទ្យាល័យ
- បានរៀបចំអបអរសាទរខួបអនុស្សាវរីយ៍ទិវានារីអន្តរជាតិ ០៨ មីនា ជារៀងរាល់ឆ្នាំ ដល់មន្ត្រីជានារីនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីចិញ្ចឹមកូនបែបវិជ្ជមាន ដល់មន្ត្រីនៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មន្ត្រីការិយាល័យសុខុមាលភាពសង្គមទាំង២៥ រាជធានី ខេត្ត
- បានរៀបចំ និងដាក់ឱ្យអនុវត្តនូវបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល និងឧបករណ៍ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តគោលនយោបាយនិងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មជួញដូរមនុស្ស និងសង្គ្រោះជនរងគ្រោះ។ តាមរយៈគោលនយោបាយនិងបទដ្ឋាន ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ៤ ៦៩៤នាក់ ត្រូវបានសង្គ្រោះ អប់រំប្រឹក្សាយោបល់ បញ្ជូនទៅស្តារនីតិសម្បទា និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមមណ្ឌលរបស់អង្គការ និងជនរងគ្រោះចំនួន ១ ២៩៥នាក់ ត្រូវធ្វើសមាហរណកម្មទៅសហគមន៍ និងតាមដានបន្តចំនួន ៣៩១នាក់ និងបិទករណីចំនួន ២៤៨នាក់។ ទន្ទឹមនោះ បានកសាងមណ្ឌលសំចតប៉ោយប៉ែតសម្រាប់ទទួលទុកដាក់ជនរងគ្រោះ និងងាយរងគ្រោះដែលទទួលបានពីអាជ្ញាធរថៃ គិតមក

ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ មណ្ឌលសំចតបានទទួលពលករចំណាកស្រុកសរុបចំនួន ១៣១ ៥៩៥នាក់ និងបានសម្ភាសកំណត់អត្តសញ្ញាណរកឃើញជនរងគ្រោះ និងងាយរងគ្រោះចំនួន ៦៨៨នាក់ បានទទួលជនរងគ្រោះមាតុភូមិនិវត្តន៍ពីប្រទេសនានាចំនួន ១ ៤០២នាក់ និងបានធ្វើមាតុភូមិនិវត្តន៍ ដោយអំពើជួញដូរមនុស្សត្រឡប់ទៅប្រទេសកំណើតវិញចំនួន ៣៤នាក់ ។

**តារាងទី១.លទ្ធផលសម្រេចបានអនុកម្មវិធីទី១.១**

| ល.រ | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២១ | |
| ១ | គ្រួសាររងគ្រោះដោយដាច់ស្បៀង ទឹទ័លក្រ គ្រោះមហន្តរាយ នៅតាមសហគមន៍ បានទទួលជំនួយសង្គ្រោះបន្ទាន់ | គ្រួសារ | ៦២ ៤៧៦ | ៥៦ ១៩៩ | ៣១ ៤២៨ | ១០១ ៤៧៣ | ២៨ ៧១៦ | ២៨០ ២៩២ |
| ២ | ប្រជាជនក្រីក្រនិងងាយរងគ្រោះដែលរងផលប៉ះពាល់ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ ១៩ | គ្រួសារ | - | - | - | ៦៨១ ៩៩៩ | ៦៨៤ ៧៧១ | |
| ៣ | ជនអនាថាដែលបានធ្វើសមាហរណកម្មទៅសហគមន៍វិញ ឬបញ្ជូនត្រឡប់ទៅសហគមន៍វិញ | នាក់ | ២៥៤ | ២ ៥០៩ | ១ ២៩១ | ៥៤៥ | ៥៤១ | ៥ ១៤០ |
| ៤ | ជនអនាថាដែលទទួលបានសេវាគាំពារ | នាក់ | ១២៤៤ | ២ ០៨៥ | ១ ៧៥៨ | ៣០៤៥ | ១ ២៩៥ | ៩ ៤២៧ |
| ៥ | ជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារផ្ទុកមេរោគអេដស៍ជំងឺអេដស៍ដែលទទួលសេវាថែទាំគាំទ្រតាមសហគមន៍ | នាក់ | ២ ៧៥៨ | ៤ ២៨៥ | ១ ៨៦៧ | ៣៣៦ | ១៩ | ៩ ២៦៥ |
| ៦ | ជនវិបល្លាសស្មារតីទទួលបានសេវាព្យាបាល និងថែទាំ ក្នុងមជ្ឈមណ្ឌល | នាក់ | - | - | ៤៧ | ៦៥ | ៧០ | |
| | ជនវិបល្លាសស្មារតីទទួលបានការបញ្ជូនត្រឡប់ ឬសមាហរណកម្មទៅគ្រួសារ ឬសហគមន៍ | នាក់ | - | - | - | ០៣ | ០៤ | ០៧ |
| ៧ | ស្ត្រីមានផ្ទៃពោះនៅក្នុងគ្រួសារក្រីក្រទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ[1] | នាក់ | - | - | - | ៤៩ ១៨៦ | ៣៧ ៨២៦ | ៨៧ ០១២ |
| ៨ | កុមារអាយុ ០-២ឆ្នាំ នៅក្នុងគ្រួសារក្រីក្រទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ[2] | នាក់ | - | - | - | ២៨ ៣៣៣ | ១៤ ៦៥៥ | ៤២ ៩៨៨ |
| ៩ | ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ រំលោភបំពានផ្លូវភេទ ទទួលបានការស្តារនីតិសម្បទា | នាក់ | ៧២០ | ៨៤៨ | ៩៦៨ | ៣៧១ | ១ ៧៨៧ | ៤ ៦៩៤ |
| ១០ | ជនរងគ្រោះ ដោយអំពើជួញដូរមនុស្សដែលត្រូវបានគាំពារ និងជួយសង្គ្រោះ | នាក់ | ០ | ០ | ៥៧៩ | ៤៦ | ១៤៣ | ៧៦៨ |

[1] CTP-MIS: Cash Transfer Program Management Information System
[2] CTP-MIS: Cash Transfer Program Management Information System

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១១ | ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានធ្វើមាតុភូមិនិវត្តន៍ទៅប្រទេសខ្លួនវិញ | នាក់ | ៣ | ២ | ៩ | ១៥ | ៥ | ៣៤ |
| ១២ | ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានធ្វើមាតុភូមិនិវត្តន៍ពីក្រៅប្រទេស | នាក់ | ២៨៨ | ២២២ | ២៩០ | ២២០ | ៣៨២ | ១ ៤០២ |
| ១៣ | ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវទទួលបានការធ្វើសមាហរណកម្មទៅតាមសហគមន៍វិញ | នាក់ | ១៤៧ | ៣៤៥ | ៤០៣ | ១០៤ | ២៩៦ | ១ ២៩៥ |
| ១៤ | ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានផ្តល់នូវសេវាក្រោយធ្វើសមាហរណកម្ម | នាក់ | ៩៥ | ១១៧ | ០ | ១២២ | ៥៧ | ៣៩១ |
| ១៥ | ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានបិទករណី | នាក់ | ៥៣ | ៦៩ | ២៧ | ២៣ | ៧៦ | ២៤៩ |

(ប្រភព÷ ទិន្នន័យរដ្ឋបាលក្រសួង ស.អ.យ.)

## អភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា

- ក្រសួងបានរៀបចំទិវាកុមារអន្តរជាតិ ១មិថុនា និងទិវាពិភពលោកប្រឆាំងពលកម្មកុមារនិងទិវាកុមារកម្ពុជា ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជារៀងរាល់ឆ្នាំ
- បានពង្រឹងពង្រីកយន្តការតាមដាន និងអនុវត្តសិទ្ធិកុមារ តាមក្រសួង ស្ថាប័ន និងរាជធានី ខេត្ត និងបានចេញគោលការណ៍ណែនាំស្តីពីការអនុវត្តអនុសាសន៍របស់អង្គការសហប្រជាជាតិ ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ
- បានរៀបចំរបាយការណ៍ ស្តីពីស្ថានភាពនៃការអនុវត្តសិទ្ធិកុមារជារៀងរាល់ឆ្នាំ និងរៀបចំរបាយការណ៍ឆ្លើយតបទៅនឹងកម្រងសំណួររបស់គណៈកម្មាធិការសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិពាក់ព័ន្ធនឹងរបាយការណ៍ជាតិលើកទី១និងទី២ ស្តីពីការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ និងស្តីពីការជួញដូរកុមារ ការធ្វើពេស្យាចារកុមារនិងរូបភាពអាសអាភាសកុមារ និងរបាយការណ៍ឆ្លើយតបទៅនឹងសេចក្តីសម្រេចចិត្តមហាសន្និបាត អ.ស.ប លេខ ៦៩/១៥៩ ស្តីពីការការពារកុមារពីការសម្លុតគម្រាមកំហែង ដើម្បីផ្ញើទៅតំណាងពិសេសអង្គការសហប្រជាជាតិ និងរបាយការណ៍ជាតិគួបលើកទី៤ ទី៥ និងទី៦ ស្តីពីការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិកុមារ
- ដើម្បីលើកកម្ពស់ការគោរពសិទ្ធិកុមារ និងការពារឧត្តមប្រយោជន៍កុមារ សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារត្រូវបានតាក់តែងឡើង និងពិនិត្យ កែសម្រួលជាបន្តបន្ទាប់តាមរយៈសិក្ខាសាលានិងកិច្ចប្រជុំនានា ក្រៅពីនេះឯកសារមួយចំនួនទៀតក៏ត្រូវបានរៀបចំ និងប្រកាសដាក់ឱ្យអនុវត្ត មានជាអាទិ៍ ផែនការសកម្មភាពជាតិ ស្តីពីការអភិវឌ្ឍកុមារ ឆ្នាំ២០១៦-២០១៨ គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ២០១៩-២០២៩ ផែនការសម្រាប់អនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ និងផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ២០២១-២០២៥។ បានពង្រឹងសមត្ថភាពមន្ត្រីរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធតាមរយៈការរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល និងបានរៀបចំកិច្ចពិភាក្សាតុមូលតាមស្ថានីយ៍វិទ្យុ និងទូរទស្សន៍ សំដៅផ្សព្វផ្សាយ បញ្ជ្រាបការយល់ដឹងអំពីសិទ្ធិកុមារឱ្យបានកាន់ទូលំទូលាយ ជាពិសេស ការបញ្ជ្រាបអំពីតួនាទីគ្រួសារ និងសហគមន៍ ក្នុងការធានានូវឧត្តមប្រយោជន៍របស់កុមារ
- កម្មាធិការអាស៊ានដើម្បីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC) ផ្នែកសិទ្ធិកុមារបានអនុវត្តគម្រោង "យុទ្ធនាការផ្សព្វផ្សាយ ស្តីពីផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុមកលើស្ត្រី និងកុមារក្នុងតំបន់អាស៊ាន" ដោយផលិតបានសៀវភៅផ្នត់(Booklet) និងវីដេអូអប់រំជាគំនូរជីវចល ស្តីពីផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុមកលើស្ត្រី និងកុមារក្នុងតំបន់អាស៊ាន ព្រមទាំងបានផ្សព្វផ្សាយទៅគ្រប់អង្គភាពអាស៊ាន និងតាមគេហទំព័ររបស់ ACWC
- បានអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ និងបទដ្ឋានអប្បបរមា ស្តីពីការថែទាំជំនួសចំពោះកុមារ អនុក្រឹត្យលេខ ១១៩អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងមណ្ឌល

ថែទាំកុមារ និងអនុក្រឹត្យលេខ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៧ នៃអនុក្រឹត្យលេខ១១៦ អនក្រ.បក ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ ដោយបានដំឡើងប្រាក់ម្ហូបអាហារពី ៤៥.០០០៛/ខែ ទៅ ១៥០.០០០៛/ខែ និងលិខិតបទដ្ឋានគតិផ្សេងៗទៀត។ បានទទួលកុមារកំព្រា និងកុមាររងគ្រោះ ឱ្យស្នាក់នៅក្នុងមណ្ឌលថែទាំចំនួន១៩៩មណ្ឌល មានកុមារសរុបចំនួន ៥ ៤៤០នាក់ កុមារី ២ ៥៦៩នាក់ និងយុវជនវ័យក្មេង (អាយុ១៨ឆ្នាំឡើង) ១ ៧១៦នាក់ ស្រី ៨៨៧នាក់ ក្នុងនោះមណ្ឌលថែទាំដែលគ្រប់គ្រងនិងគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាលមានចំនួន ១៧៨មណ្ឌលមានកុមារ ៤ ៧៣៤នាក់ កុមារី ២ ២៧៩នាក់ និងយុវជនវ័យក្មេង (អាយុ១៨ឆ្នាំឡើង) ១ ៣៩០នាក់ ស្រី ៧២២នាក់ មណ្ឌលថែទាំរបស់រដ្ឋមានចំនួន ២១ មានកុមារចំនួន ៧០៨នាក់ កុមារី ២៩០នាក់ និងយុវជនវ័យក្មេង (អាយុ១៨ឆ្នាំឡើង) ចំនួន ៣២៦នាក់ ស្រី ១៦៥នាក់។ កន្លែងថែទាំបែបសហគមន៍មានចំនួន ១០១កន្លែង មានកុមារចំនួន ២ ១៨៦នាក់ កុមារី ១ ០៤៧នាក់ និងយុវជនវ័យក្មេង (អាយុ១៨ឆ្នាំឡើង) ៥២១នាក់ ស្រី ២៧២នាក់

- ដើម្បីពង្រឹងប្រសិទ្ធភាព និងគុណភាពការគ្រប់គ្រងមណ្ឌលថែទាំកុមារ ក្រសួងបានបង្កើតប្រព័ន្ធន័យអធិការកិច្ចកន្លែងថែទាំកុមារដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល និងបង្កើតប្រព័ន្ធគ្រប់គ្រងករណីកុមារតាមប្រព័ន្ធបច្ចេកវិទ្យា Primero និងបានបណ្តុះបណ្តាលដល់មន្ត្រីទទួលបន្ទុកនៅតាមមន្ទីរ ស.អ.យ. រាជធានី ខេត្ត និងការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គម ក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេស ព្រមទាំងបានធ្វើអធិការកិច្ចមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល។ តាមរយៈពិន្ទុអធិការកិច្ចឆ្នាំ២០១៩ បានបង្ហាញថា មណ្ឌលចំនួន ៩៨ ស្មើនឹង ៤២,២% អនុវត្តស្របតាមបទដ្ឋាន មណ្ឌលចំនួន ៥៩ អនុវត្តមិនស្របតាមបទដ្ឋាន និងមណ្ឌលចំនួន ៧៥ អនុវត្តក្រោមបទដ្ឋានអប្បបរមាធ្ងន់ធ្ងរ
- បានអនុវត្តផែនការសកម្មភាព ដើម្បីធ្វើឱ្យប្រសើរឡើងនូវការថែទាំកុមារ និងសមាហរណកម្មកុមារចំនួន ៣០% ពីមណ្ឌលថែទាំកុមារទៅកាន់គ្រួសាររបស់ពួកគេវិញដោយសុវត្ថិភាព។ គិតត្រឹមឆ្នាំ២០១៩ មណ្ឌលថែទាំកុមារនៅសល់ចំនួន ២៣២មណ្ឌល ដែលមានកុមារសរុបចំនួន ៦.៧៧៨នាក់ (ស្រី ៣ ៣១៧នាក់) ដូច្នេះ បើធៀបនឹងឆ្នាំ២០១៥ មណ្ឌលថែទាំកុមារបានថយចុះចំនួន ១៧៤កន្លែង (៤៣%) និងកុមាររស់នៅក្នុងមណ្ឌលថែទាំបានថយចំនួន ៩ ៨០២នាក់ (៥៩%)។ ក្នុងចំណោមមណ្ឌលថែទាំកុមារ ១៧៤ ដែលថយចុះ ដោយសារ មណ្ឌលថែទាំចំនួន ៧៧ បានបិទលែងដំណើរការ (ក្នុងនោះមណ្ឌលចំនួន ២ បានបិទដោយសារការអនុវត្តមិនស្របតាមបទដ្ឋានអប្បបរមា ស្តីពីការថែទាំជំនួសចំពោះកុមារ មណ្ឌលចំនួន ៤៣ បានបិទដោយសារខ្វះមូលនិធិ និងមណ្ឌលចំនួន ៣២ផ្សេងទៀត បានបិទដោយសារមូលហេតុផ្សេងៗ មណ្ឌលចំនួន ២៤ បានបង្វែរទៅជាសេវាថែទាំតាមសហគមន៍ និងមណ្ឌលចំនួន ៧៣ បានផ្លាស់ទៅជាសេវាថែទាំដែលពុំមែនជាមណ្ឌល។ កុមារចំនួន ១ ៤១៩នាក់ ស្មើនឹង ១២% ធៀបនឹងកុមារចំនួន ១១ ៧៨៨នាក់ រស់នៅក្នុងមណ្ឌលថែទាំនៅក្នុងរាជធានី ខេត្ត គោលដៅទាំង ៥ ត្រូវបានជួយគាំទ្រដើម្បីសមាហរណកម្ម។ ទន្ទឹមនោះ ក្រសួងបានចេញសេចក្តីណែនាំ ស្តីពីតួនាទី ភារកិច្ច របស់មន្ត្រីសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ។
- ក្រសួងបានចេញប្រកាសលេខ ១១៩ ស.អ.យ. ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២១ ស្តីពីនីតិវិធីអនុវត្តការថែទាំកុមារដោយសាច់ញាតិ និងឪពុកម្តាយធម៌។ ក្រសួងសម្របសម្រួលលើការងារសុំកូនក្នុងប្រទេសដោយតុលាការខេត្តបាត់ដំបងបានចេញដីការសម្រេចអំពីការបង្កើតការសុំកូនពេញលេញបានចំនួន ៥នាក់។ ក្រសួងបានទទួលដីការលេខ៦០៧ "ជ".ដ.ម ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២១ ក្នុងសំណុំរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹងលេខ: ៥៨៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨ សម្រេចជ្រើសតាំងប្រធាននាយកដ្ឋាន

សុខុមាលភាពកុមារ ជាអ្នកអាណាព្យាបាលសម្រាប់អនីតិជនចំនួន ២៨នាក់ ដែលកំពុងស្នាក់នៅមណ្ឌលបុរីទារក និងកុមារជាតិ

- បានផ្តល់វិញ្ញាបនបត្រទទួលស្គាល់មណ្ឌលថែទាំកុមារជូនអង្គការមិនមែនរដ្ឋាភិបាលចំនួន១០០មណ្ឌល និងបានបណ្តុះបណ្តាលគុណវុឌ្ឍិនៃអង្គការសុវត្ថិភាពនៃកុមារ ដល់បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលបានចំនួន ៦អង្គការ សរុបអ្នកចូលរួមចំនួន ១០០នាក់
- ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ កម្ពុជាបានចូលជាសមាជិកដៃគូសកលដើម្បីបញ្ចប់អំពើហិង្សាលើកុមារ ក្រសួងបានរៀបចំផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ បង្កើតយន្តការដឹកនាំការងារ និងបើកយុទ្ធនាការ "គ្រួសាររឹងមាំ" នៃយុទ្ធសាស្ត្រ Cambodia Protect ដើម្បីលុបបំបាត់អំពើហិង្សាលើកុមារ និងទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់។ យុទ្ធនាការនេះ ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយតាមរយៈវិទ្យុ ទូរទស្សន៍ សារសម្លេងតាមទូរស័ព្ទ បណ្តាញសង្គមហ្វេសបុក Strong Family និងគេហទំព័រ www.strongfamily.mosvy.gov.kh និងបានរៀបចំសន្និសីទថ្នាក់តំបន់ឆ្ពោះទៅអនុវត្តយុទ្ធសាស្ត្រ INSPIRE (**I** : Implementation and enforcement of laws; **N** : Norms and values; **S** : Safe environments; **P** : Parent and caregiver support; **I** : Income and economic strengthening; **R** : Response and support services; and **E** : Education and life skills) ដែលមានអ្នកចូលរួមចំនួន ១៥០នាក់ មកពីប្រទេសចំនួន ២១ ដើម្បីសិក្សា និងចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមក
- បានទទួលរបាយការណ៍តាមដានវឌ្ឍនភាពកូនចិញ្ចឹមចំនួន ១ ៩៧៣ករណី មកពីប្រទេសអ៊ីតាលី ១ ៩០១ករណី អូទ្រីស ៤៤ករណី ម៉ាល់តា ១៩ករណី ហូឡង់ ១ករណី បារាំង ១ករណី បែលហ្សិក ២ករណី អេស្ប៉ាញ ១ករណី និងអាមេរិក ៣ករណី។ តាមរបាយការណ៍ ស្ថានភាពកុមារដែលបានសុំទៅក្រៅប្រទេសមានលក្ខណៈល្អប្រសើរទាំង សុខភាព ការរស់នៅ និងការសិក្សារៀនសូត្រ
- បានកំពុងសាងសង់មជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយសារស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ កែវផុស ស្រុកកំពង់សិលា ខេត្តព្រះសីហនុ រហូតមកដល់ពេលនេះហេដ្ឋារចនាសម្ព័ន្ធជាច្រើនត្រូវបានកសាងរួចរាល់ ហើយកំពុងបានទទួលជនរងគ្រោះដោយសារគ្រឿងញៀនស្នាក់នៅ បន្សាប និងព្យាបាល និងបានចេញប្រកាសអន្តរក្រសួង ស្តីពីលក្ខខណ្ឌនិងទម្រង់បែបបទនៃការស្នើសុំបង្កើតមណ្ឌលសម្រាប់ការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងគោលការណ៍ណែនាំ ស្តីពីការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។ បានចេញប្រកាសបញ្ចូលជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន ៣១ ៥៤៣នាក់ និងចេញប្រកាសបញ្ចេញជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន ៣០ ៣១៩នាក់
- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ត្រូវបានផ្សព្វផ្សាយដល់មន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ដើម្បីជំរុញអនុវត្តច្បាប់នេះ ក្រសួងបានរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិ ២០១៨-២០២០ សាងសង់មណ្ឌលយុវនីតិសម្បទា រៀបចំទម្រង់របាយការណ៍ប៉ាន់ប្រមាណសុខុមាលភាពនិងស្ថានភាពរបស់អនីតិជន ប្រកាសលេខ ១៥៥ ស.អ.យ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះមណ្ឌលយុវនីតិសម្បទា អនុក្រឹត្យលេខ ១៥៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទា តែងតាំង និងទទួលស្គាល់ភ្នាក់ងារសង្គមកិច្ចទាំង ២៥រាជធានី ខេត្ត តាមប្រកាសលេខ ១០១ ស.អ.យ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ សរុបចំនួន ៥០នាក់
- បានបណ្តុះបណ្តាលច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងការងារសង្គមដល់មន្ត្រីសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ បានចំនួន១៩៩ ដែលមានអ្នកចូលរួមសរុបចំនួន ២២៥នាក់ ឆ្នាំ២០១៩
- បានផ្សព្វផ្សាយពីការប្រើប្រាស់ទម្រង់របាយការណ៍ប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនទំនាស់នឹងច្បាប់ ទូទាំង ២៥រាជធានី ខេត្ត ដោយមានការចូលរួមពីព្រះរាជអាជ្ញាអមសាលាដំបូង នគរបាលយុត្តិធម៌ ថ្នាក់ដឹកនាំនៃមន្ទីរ ស.អ.យ. និងភ្នាក់សង្គមកិច្ចសរុបចំនួន ១៦២នាក់ ស្រី៦១នាក់

- បានអប់រំកុមារ យុវជន ទប់ស្កាត់បាតុភាពអសកម្មនានាក្នុងសង្គម រួមចំណែកលើកស្ទួយសីលធម៌ សុជីវធម៌ និងការពារសិទ្ធិកុមារ និងជនរងគ្រោះដែលប្រើប្រាស់គ្រឿងញៀន។ បានសហការជាមួយក្រសួងមហាផ្ទៃ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ផ្តល់សេវាអប់រំក្រៅប្រព័ន្ធ និងបណ្តុះបណ្តាលវិជ្ជាជីវៈដល់អនីតិជនទំនាស់នឹងច្បាប់ និងបានផ្តល់សេវាសង្គមកិច្ចដល់កូនតាមម្តាយក្នុងពន្ធនាគារដែលមានអាយុលើសពី៣ឆ្នាំចំនួន ២៥នាក់។

**តារាងទី២.លទ្ធផលសម្រេចបានអនុកម្មវិធីទី១.២**

| ល.រ | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | |
| ១៦ | កុមារកំព្រា និង កុមារងាយរងគ្រោះដែលរស់នៅក្នុងមណ្ឌលថែទាំកុមារ | នាក់ | ១៦ ៥៧៩ | ៧ ៦៣៤ | ៦ ៧៧៨ | ៦ ៧៧៨ | ៥ ៤៤០ | |
| ១៧ | កុមារកំព្រា និងកុមារងាយរងគ្រោះដែលបានធ្វើសមាហរណកម្មទៅសហគមន៍វិញ | នាក់ | ៧៣៨ | ១ ១៤០ | ១ ៤១៩ | ១ ៤១៩ | ១ ៤៤៧ | |
| ១៨ | កុមាររងគ្រោះដែលទទួលបានការថែទាំដោយក្រុមគ្រួសារ និងសហគមន៍ | នាក់ | ៩ ៦០៨ | ១០ ៧៤៨ | ២ ៨០០ | ២ ៨០០ | ២ ១៨៦ | |
| ១៩ | កុមារដែលត្រូវបានសុំកូនអន្តរប្រទេស | នាក់ | ០០ | ០០ | ០០ | ០០ | ០០ | |
| ២០ | ទីភ្នាក់ងារសុំកូនអន្តរប្រទេស ដែលទទួលបានការអនុញ្ញាតធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស | ទីភ្នាក់ងារ | ០០ | ០០ | ០០ | ០០ | ០០ | |
| ២១ | អនីតិជនប្រព្រឹត្តល្មើសច្បាប់ដែលជាប់ក្នុងពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែ និងមណ្ឌលយុវនីតិសម្បទាទទួលបានសេវាស្តារនីតិសម្បទា | នាក់ | ១ ៤២១ | ១ ៥៦៥ | ១ ៦៨១ | ១ ៦២១ | ១ ៤០៤ | |
| ២២ | កូនតាមម្តាយដែលមានអាយុចាប់ពី៣ (បី) ឆ្នាំឡើងទៅនៅក្នុងពន្ធនាគារ ត្រូវបានទទួលសេវាសង្គមកិច្ច | នាក់ | ០៥ | ០៧ | ០៨ | ០៧ | ១០ | ៣៧ |
| ២៣ | ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនបានស្តារនីតិសម្បទា | នាក់ | ១០ ១៧៨ | ៨ ០៩៧ | ១១ ៩១៣ | ១១ ៥៣៦ | ១១ ៨៤៣ | |
| ២៤ | ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនបានធ្វើសមាហរណកម្មទៅសហគមន៍វិញ | នាក់ | ៦ ៧២២ | ៧ ៦៧៧ | ៧ ៩០៥ | ៧ ៥៥១ | ៥ ០៦៧ | ៣៤ ៩២២ |

(ប្រភព÷ ទិន្នន័យរដ្ឋបាលក្រសួង ស.អ.យ.)

**អភិវឌ្ឍសុខុមាលភាពជនពិការ**

- បាននឹងកំពុងប្រមូលធាតុចូលក្នុងការធ្វើវិសោធនកម្មច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនមានពិការភាព
- បានរៀបចំរបាយការណ៍លើកដំបូងនៃការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធជនពិការ
- បានប្រកាសជាផ្លូវការដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីពិការភាព ២០១៤-២០១៨ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ តាមរយៈផែនការនេះ ក្រសួងបានរៀបចំរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិឆ្នាំ២០១៥ និងសេចក្តីព្រាងរបាយការណ៍បញ្ចប់អាណត្តិឆ្នាំ២០១៤-២០១៨ និងបានដាក់ឲ្យ

អនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ ព្រមទាំងបានផ្សព្វផ្សាយដល់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន ១៥ រាជធានី ខេត្ត

- បានដាក់ឲ្យប្រើប្រាស់ប្រកាសអន្តរក្រសួង ស្តីពីលក្ខខណ្ឌនៃការចេញប័ណ្ណបើកបរយានយន្តសម្រាប់ជនពិការ រួមទាំងសៀវភៅគោលការណ៍ណែនាំណែនាំ ស្តីពីជំនួយផ្នែកច្បាប់សម្រាប់ជនពិការ
- បានអនុវត្តគម្រោងសាកល្បងបរិយាបន្នពិការភាព និង Gender ដល់ក្រុមប្រឹក្សាកម្មភាពជនពិការខេត្ត ចំនួន៥ គឺខេត្តបាត់ដំបង សៀមរាប កំពង់ចាម ត្បូងឃ្មុំ និងកំពង់ស្ពឺ
- បានបង្កើតក្រុមការងារសកម្មភាពជនពិការតាមក្រសួង ស្ថាប័ន និងក្រុមប្រឹក្សាសកម្មភាពជនពិការតាមរាជធានី ខេត្ត និងបានរៀបចំសិក្ខាសាលាបញ្ជ្រាបការយល់ដឹងអំពីអនុសញ្ញា ស្តីពីសិទ្ធិជនពិការ ទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិកឆ្នាំ២០១៣-២០២២ ផែនការយុទ្ធសាស្ត្រជាតិ ស្តីពីពិការភាព បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលជំនាញបរិយាប័ន្នពិការភាព របៀបធ្វើបរិយាបន្នពិការភាពដល់មន្ត្រីនៃអគ្គលេខាធិការដ្ឋាន ក.ស.ជ. ក្រុមការងារ ក.ស.ជ. តាមក្រសួង ស្ថាប័ន និង ក.ស.ជ. ថ្នាក់រាជធានីខេត្ត យ៉ាងទូលំទូលាយ
- បានសម្ពោធដាក់ឲ្យប្រើប្រាស់ជម្រាលគំរូក្នុងឃុំចំនួន២២ក្នុងខេត្តចំនួន៥ និងវីដេអូអប់រំ ស្តីពីបទដ្ឋានបច្ចេកទេសហេដ្ឋារចនារូបវ័ន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការ និងបានបណ្តុះបណ្តាលស្តីពីបទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនពិការដល់អ្នកពាក់ព័ន្ធ
- បានចូលរួមកិច្ចប្រជុំក្រុមការងារក្នុងក្របខ័ណ្ឌអាស៊ានចំនួន០៦លើក ស្តីពីការកសាងផែនការមេសម្រាប់ការបញ្ជ្រាបសិទ្ធិជនពិការក្នុងសហគមន៍អាស៊ាន ឆ្នាំ២០២៥
- បានចូលរួមសន្និសីទលើកទី១១ នៃរដ្ឋភាគីអនុសញ្ញា ស្តីពីសិទ្ធិជនពិការនៅអង្គការសហប្រជាជាតិ ការិយាល័យកណ្តាលទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក កាលពីថ្ងៃទី១២ ដល់១៤ ខែមិថុនា ឆ្នាំ២០១៨ ក្រោមប្រធានបទ "មិនអនុញ្ញាតឱ្យនរណាម្នាក់នៅក្រៅការអនុវត្តយ៉ាងពេញលេញនៃអនុសញ្ញា ស្តីពីសិទ្ធិជនពិការ" ក្នុងនោះ កម្ពុជាទទួលបានការគាំទ្រ១៨៣សម្លេង លើ១៨៨សម្លេង ចូលជាសមាជិក ECOSOC នៃអង្គការសហប្រជាជាតិ
- បានរៀបចំទិវាជនពិការកម្ពុជា និងទិវាជនពិការអន្តរជាតិ ទិវាគ ថ្លង់ និងទិវាអូទីហ្ស៊ឹមនិងដោនស៊ីនដ្រូម សម្រាប់ជនពិការ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជារៀងរាល់ឆ្នាំ
- បានបណ្តុះបណ្តាលវិជ្ជាជីវៈ និងផ្តួចផ្តើមបង្កើតមុខរបរនៅតាមសហគមន៍ដល់ជនពិការបាន ៤៤៧នាក់ លើជំនាញ កាត់ដេរសម្លៀកបំពាក់និងកាបូប អេឡិចត្រូនិច ជួសជុលម៉ាស៊ីន អ៊ុតសក់ធ្វើមុខនិងសម្អាងការ ចម្លាក់ កសិកម្ម ជួសជុលទូរស័ព្ទ និងជំនាញគ្រប់គ្រងអាជីវកម្មនិងអនាម័យ។ ទន្ទឹមនេះ បានដោះស្រាយការងារ និងមុខរបរជូនជនពិការបាន ៣៨៥នាក់
- អនុវត្តតាមអនុក្រឹត្យ ស្តីពីការជ្រើសរើសជនពិការចូលបម្រើការងារ ក្រសួង ស.អ.យ. បានជំរុញក្រសួង ស្ថាប័នរដ្ឋ ក្នុងការជ្រើសរើសជនពិការចូលបម្រើការងារតាមអត្រា បច្ចុប្បន្ន ជនពិការ ៣ ៦២១នាក់ កំពុងបម្រើការងារតាមក្រសួង ស្ថាប័នរដ្ឋចំនួន៤៣ និងជនពិការ ៥ ២៣៥នាក់ កំពុងបម្រើការងារនៅក្នុងរោងចក្រ សហគ្រាសវិស័យឯកជន
- បានផ្តល់របបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ ១៦ ៨០២នាក់ ទៅតាម៣កម្រិត កម្រិត១ឧបត្ថម្ភ១២ខែ កម្រិត២ឧបត្ថម្ភ៦ខែ និងកម្រិត៣ឧបត្ថម្ភ៣ខែ ដោយមួយខែៗឧបត្ថម្ភ ២០ ០០០៛ ដោយក្នុងនោះ កម្រិត១មាន ១១ ១៦៦នាក់ និងកម្រិត២ មាន ៥ ៦៣៦នាក់ និងបានលុបឈ្មោះជនពិការចេញពីរបបឧបត្ថម្ភជនពិការក្រីក្រនៅសហគមន៍ ៩២៩នាក់
- ដើម្បីអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ ក្រសួងបានកំពុងរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកំណត់អត្តសញ្ញាណជនពិការតាមបែបគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន។ បានផលិតវីដេអូណែនាំចំនួន១០ សម្រាប់ណែនាំមន្ត្រីដែលត្រូវចុះអនុវត្តកំណត់អត្តសញ្ញាណកម្មពិការភាពតាមឃុំសង្កាត់ និងបានរៀបចំដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាពិការភាព (DMIS: Disability Management Information System) និងប្រកាសដាក់ឱ្យដំណើរការអេប App កម្មវិធីចំនួន ០២ គឺ កម្មវិធីអត្តសញ្ញាណកម្មពិការភាព

(DIP Cambodia) និងកម្មវិធីឱកាស (OAKAS) ការងារនិងមុខរបរប្រកបដោយបរិយាបន្ន សម្រាប់ជនមានពិការភាព ព្រមទាំង បានបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តកម្មវិធីកំណត់អត្តសញ្ញាណកម្មពិការភាព ចំនួន ៤ ៩០៦នាក់ ស្រី ១ ៧៧៦នាក់ និងមេឃុំចៅ សង្កាត់ ចំនួន ១ ៤៩២នាក់

- បានផលិតសៀវភៅមគ្គុទ្ទេសក៍គតិយុត្ត ស្តីពីកាតព្វកិច្ចរបស់និយោជកក្នុងការជ្រើសរើសនិយោជិតពិការចូលបម្រើការងារជាបីភាសា (ខ្មែរ អង់គ្លេស និងចិន) ចំនួន ១០ ០០០ក្បាល ដើម្បីចែកជូនដល់ក្រុមហ៊ុន រោងចក្រ សហគ្រាស ទូទាំងប្រទេស
- ដែលរហូតមកដល់ពេលនេះ ជនពិការចំនួន ២២៥ ២០២នាក់ ត្រូវបានសម្ភាសដើម្បីកំណត់អត្តសញ្ញាណជនពិការតាមបែបគំរូសង្គម និងសិទ្ធិជាមូលដ្ឋាននៅតាមឃុំ សង្កាត់ ដោយក្នុងនោះ ជនពិការចំនួន ៦៣ ៥៣៨នាក់ ត្រូវបានក្រសួងអនុម័តទទួលស្គាល់
- បានចេញប្រកាស ស្តីពីការដាក់ឱ្យប្រើប្រាស់នូវឯកសារណែនាំគោល នីតិវិធីចុះបញ្ជិកា ស្តីពីនីតិវិធីអធិការកិច្ចលើវិស័យពិការភាពនៃព្រះរាជាណាចក្រកម្ពុជា និងបានផ្សព្វផ្សាយទៅតាមរាជធានី ខេត្ត ព្រមទាំងបានចុះពិនិត្យ វាយតម្លៃរោងចក្រ សហគ្រាស និងចុះបញ្ជិកាជូនរោងចក្រ សហគ្រាសសរុបចំនួន ១៥០។

តារាងទី៣.លទ្ធផលសម្រេចបានអនុកម្មវិធីទី១.៣

| ល.រ | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | |
| ២៨ | ជនពិការទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ | នាក់ | ១២៣ | ១១៧ | ១១៩ | ៥៣ | ៣៥ | ៤៤៧ |
| ២៩ | ជនពិការត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារនៅតាមស្ថាប័នរដ្ឋ(២%) | នាក់ | ២ ៧៣៧ | ២ ៨៣៩ | ២ ៨៦០ | ៣ ០៩៥ | ៣ ៦២១ | |
| ៣០ | ជនពិការត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារនៅតាមស្ថាប័នឯកជន (១%) | នាក់ | ២ ៩៦២ | ៣ ០៥៥ | ៣ ៣១៥ | ៣ ៨៩១ | ៥ ២៣៥ | |
| ៣១ | ជនពិការក្រីក្រនៅតាមសហគមន៍ទទួលបានរបបឧបត្ថម្ភគោលនយោបាយ | នាក់ | ៦ ៦៥៨ | ១៣ ៤៦៦ | ១៤ ១១៦ | ១៦ ៣៧៣ | ១៦ ៨០២ | |

(ប្រភព÷ ទិន្នន័យរដ្ឋបាលក្រសួង ស.អ.យ.)

**អភិវឌ្ឍសុខុមាលភាពមនុស្សចាស់**

- បានរៀបចំ និងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវគោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០ និងបានរៀបចំផែនការសកម្មភាព ២០១៨-២០២០ សម្រាប់អនុវត្តគោលនយោបាយនេះផងដែរ
- បានចេញប្រកាស ស្តីពីលក្ខខណ្ឌ និងទម្រង់បែបបទនៃការស្នើសុំអនុញ្ញាតបង្កើតមជ្ឈមណ្ឌលថែទាំមនុស្សវ័យចាស់ និងប្រកាស ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការបង្កើតមជ្ឈមណ្ឌល និងការគ្រប់គ្រងមជ្ឈមណ្ឌលថែទាំមនុស្សវ័យចាស់
- បានរៀបចំទិវាមនុស្សចាស់កម្ពុជា និងមនុស្សចាស់អន្តរជាតិ ០១តុលា ជារៀងរាល់ឆ្នាំ ដើម្បីលើកស្ទួយដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់មនុស្សវ័យចាស់
- ដើម្បីលើកកម្ពស់សេចក្តីថ្លៃថ្នូរ ជំរុញលើកទឹកចិត្តឱ្យមនុស្សចាស់ចេះសាមគ្គីគ្នា ជួយគ្នាទៅវិញទៅមក ក្រសួងបានបង្កើតសមាគមមនុស្សចាស់ ១ ៦៤៦ មានសមាជិកសរុបចំនួន ២៩៤ ៤៤០នាក់ នៅតាមរាជធានី ខេត្តទាំង ២៥
- បានឧបត្ថម្ភសាច់ប្រាក់ជូនមនុស្សចាស់អាយុពី ៦០ឆ្នាំឡើង តាមរយៈកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ជនរងគ្រោះនិងរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ ចំនួន ៣៣៨ ០៧៦នាក់

- បានសាងសង់មជ្ឈមណ្ឌលជាតិគាំពារមនុស្សចាស់រាជធានីភ្នំពេញ និងដាក់ឱ្យដំណើរការឆាប់ៗនេះ។ ទន្ទឹមនេះ ក្រសួងបានចេញប្រកាស ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិគាំពារមនុស្សចាស់ រាជធានីភ្នំពេញ និងកំពុងរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីកិច្ចគាំពារសង្គមសម្រាប់មនុស្សវ័យចាស់ក្រីក្រគ្មានទីពឹង។

តារាងទី៤.លទ្ធផលសម្រេចបានអនុកម្មវិធីទី១.៤

| ល.រ | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | |
| ៣២ | អត្រាមនុស្សចាស់ក្រីក្រគ្មានទីពឹងទទួលបានសេវាថែទាំនៅតាមសហគមន៍ | % | | | 00 | 00 | 00 | |
| ៣៣ | មនុស្សចាស់ក្រីក្រគ្មានទីពឹងទទួលបានសេវាថែទាំក្នុងមជ្ឈមណ្ឌលគាំពារមនុស្សចាស់ | នាក់ | | | 00 | 00 | 00 | |
| ៣៤ | មនុស្សចាស់ក្រីក្រគ្មានទីពឹងទទួលបានគោលរបបគាំពារសង្គម | នាក់ | | | - | - | ៣៣៨ ០៧៦ | |

(ប្រភព÷ ទិន្នន័យរដ្ឋបាលក្រសួង សអយ)

## អភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន

- បានបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជនឃុំ សង្កាត់ ១ ០២៣ មានសមាជិកសរុបចំនួន ២៤ ៤០៤នាក់ ដែលបានជួយកែលម្អជីវភាពរស់នៅរបស់អតីតយុទ្ធជន និងគ្រួសារឱ្យកាន់តែប្រសើរឡើងជាបន្តបន្ទាប់
- បានបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីនីតិវិធីប្រមូលទិន្នន័យពីស្ថានភាពជីវភាព និងតម្រូវការរបស់អតីតយុទ្ធជន និងគ្រួសារ ចំនួន ៤០០នាក់ នៅខេត្តកែប ស្វាយរៀង ត្បូងឃ្មុំ និងខេត្តកំពត
- សមាគមអតីតយុទ្ធជនកម្ពុជាបានទទួលថវិកាពីរាជរដ្ឋាភិបាលចំនួន ៤ពាន់លានរៀល/ឆ្នាំ ជូនដល់សមាគមអតីតយុទ្ធជនកម្ពុជា ដើម្បីប្រគល់ជូនដល់សមាជិកសមាគមអតីតយុទ្ធជនកម្ពុជាដែលបានទទួលមរណភាពចាប់តាំងពីឆ្នាំ២០១៦
- បានសហការជាមួយសមាគមអតីតយុទ្ធជនកម្ពុជារៀបចំប្រារព្ធទិវាអតីតយុទ្ធជនកម្ពុជា២១មិថុនា ជារៀងរាល់ឆ្នាំ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ សមាគមអតីតយុទ្ធជនកម្ពុជាបានទទួលសំណុំបែបបទស្នើសុំប្រាក់បេឡាមរណសង្គ្រោះ និងបានចេញសេចក្តីសម្រេចប្រគល់ប្រាក់បេឡាមរណសង្គ្រោះជូនដល់គ្រួសារសព ៧ ៩៨៥សព។ បើគិតពីឆ្នាំ២០០៨ រហូតដល់ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ សមាគមអតីតយុទ្ធជនកម្ពុជាបានចេញសេចក្តីសម្រេចប្រគល់ប្រាក់បេឡាមរណសង្គ្រោះជូនដល់គ្រួសារសពសរុបចំនួន ១៧ ៨៨៩សព។ បច្ចុប្បន្ន ស.អ.ក. មានសមាជិកសរុបចំនួន ៨០ ៦៩១នាក់
- បានសហការជាមួយសមាគមអតីតយុទ្ធជនកម្ពុជា រៀបចំកម្មវិធីបើកមហាសន្និបាតសហព័ន្ធអតីតយុទ្ធជនអាស៊ាន (VECONAC) លើកទី១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានសមាគមអតីតយុទ្ធជនកម្ពុជា និងកម្មវិធីបិទមហាសន្និបាតដោយឯកឧត្តមនាយឧត្តមសេនីយ៍ **គន់ គីម** ទេសរដ្ឋមន្ត្រី អនុប្រធានអគ្គលេខាធិការ ស.អ.ក. និងជាប្រធានសហព័ន្ធអតីតយុទ្ធជនអាស៊ានឆ្នាំ២០១៩ និងបានប្រារព្ធទិវាអតីតយុទ្ធជនកម្ពុជា ២១មិថុនា ជារៀងរាល់ឆ្នាំ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## កម្មវិធីទី២៖ បង្កើនប្រសិទ្ធភាពប្រព័ន្ធសន្តិសុខសង្គម និងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ

## អភិវឌ្ឍសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលប្រកបដោយប្រសិទ្ធភាព

- ដើម្បីទ្រទ្រង់ដំណើរការបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល រាជរដ្ឋាភិបាលបានបង់ភាគទាន ២៤% នៃប្រាក់បៀវត្សរ៍សរុប ដោយក្នុងនោះ បានបង់ភាគទាន ៦% ជំនួសមន្ត្រីរាជការស៊ីវិលដែលមានកាតព្វកិច្ចត្រូវបង់។ ទន្ទឹមនឹងការទ្រទ្រង់ទាំងស្រុងដោយថវិកាជាតិលើរបបសន្តិសុខសង្គម

សម្រាប់មន្ត្រីរាជការស៊ីវិល រាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់ធ្វើការកែសម្រួលដំឡើងរបបសន្តិសុខសង្គមនេះជាបន្តបន្ទាប់ ដើម្បីឱ្យស្របតាមការរីកចម្រើននៃសេដ្ឋកិច្ច និងលទ្ធភាពនៃថវិកាជាតិ

- បានរៀបចំបែបបផ្តល់របបសន្តិសុខសង្គមជូនមន្ត្រីរាជការដែលត្រូវចូលនិវត្តន៍ ១៣ ៨៤១នាក់ និងអ្នកនៅក្នុងបន្ទុកចំនួន ១២ ៣០៩នាក់ និងបានផ្ទេរការគ្រប់គ្រងទៅតាមរាជធានី ខេត្ត
- បានលុបសពនិវត្តជន និងសពជនបាត់បង់សម្បទាវិជ្ជាជីវៈសរុបចំនួន ដែលទទួលមរណភាព ៦ ៦៤៧នាក់ និងបន្តឧបត្ថម្ភប្រាក់គោលនយោបាយរបបសន្តិសុខសង្គមជូនអ្នកនៅក្នុងបន្ទុកចំនួន ៣ ៨២០នាក់
- បានកែសម្រួលកម្មប្រាក់សោធនជូននិវត្តជន ៥០៧នាក់ និងលុបឈ្មោះនិវត្តជន ៤៨នាក់ ដែលនៅបន្តបំពេញការងារនៅអង្គភាពដើម ឬប្តូរការទទួលរបបទៅស្ថិតក្រោមស្ថាប័ននីតិបញ្ញត្តិ
- បានផ្តល់គោលការណ៍រៀបចំបែបបទបើកប្រាក់របបសន្តិសុខសង្គមសម្រាប់សពមន្ត្រីរាជការស៊ីវិលដែលទទួលមរណភាព ១៥១នាក់ និងទទួលគ្រប់គ្រងកូនសពមន្ត្រីរាជការស៊ីវិល ៩២នាក់
- បានលុបអ្នកនៅក្នុងបន្ទុក ៤ ១១១នាក់ និងចុះត្រួតពិនិត្យអ្នកនៅក្នុងបន្ទុក ព្រមទាំងបើកប្រាក់របបសន្តិសុខសង្គមជូនអ្នកនៅក្នុងបន្ទុកសពនិវត្តជន សពជនបាត់បង់សម្បទាវិជ្ជាជីវៈ និងកូនក្នុងបន្ទុកមន្ត្រីរាជការស៊ីវិល ៤១ ៥០៨នាក់
- បានបើកប្រាក់របបសន្តិសុខសង្គមចុងក្រោយរបស់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈដែលទទួលមរណភាព ៦ ៤៦៤នាក់ និងបើកប្រាក់រំលឹកប្រចាំខែជូននិវត្តជន ១២ ៩៨៨នាក់
- បានផ្ទេរសិទ្ធិជូនសិទ្ធិវន្តដែលមានជំងឺស្នើសុំផ្ទេរសិទ្ធិ ៤៤៩នាក់ និងមោឃភាពលិខិតផ្ទេរសិទ្ធិ ១២៣លិខិត
- បានដំឡើងបន្ថែមប្រាក់សោធនប្រចាំខែតាមកម្រិតជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ជារៀងរាល់ឆ្នាំ មកដល់ឆ្នាំ២០២១នេះ ប្រាក់របបសន្តិសុខសង្គមប្រចាំខែទាបបំផុតចំនួន ៦៤ម៉ឺនរៀល/ខែ។ គិតជាមធ្យមក្នុងរយៈពេល៥ឆ្នាំនេះ មាននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈចំនួន ៥៦.៣៨៤នាក់[3] និងអ្នកនៅក្នុងបន្ទុកចំនួន ៤៤.៧៨៤នាក់[4] កំពុងទទួលរបបសន្តិសុខសង្គម
- នៅដើមឆ្នាំ២០១៨ ប.ជ.ស. បានសហការជាមួយបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) ដើម្បីផ្តល់តាវកាលិកថែទាំសុខភាពជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយត្រូវបានដាក់ឱ្យទទួលសេវាថែទាំសុខភាពនៅតាមបណ្តាមូលដ្ឋានសុខាភិបាលដែលមានចុះកិច្ចសន្យាជាមួយ ប.ស.ស. ចំពោះនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈដែលព័ត៌មានផ្ទាល់ខ្លួននៅក្នុងសាលាកបត្រព័ត៌មានខុសពីព័ត៌មានក្នុងអត្តសញ្ញាណប័ណ្ណ ប.ជ.ស. បានចេញវិញ្ញាបនបត្ររដ្ឋបាលបញ្ជាក់ជូនពួកគាត់សរុបចំនួន ១ ០៦៩ ដើម្បីប្រើប្រាស់សេវាធានារ៉ាប់រងថែទាំសុខភាព។

[3] 56,384នាក់ = (53,785នាក់ + 56,353នាក់+ 57302នាក់ + 58,009នាក់ + 56,472នាក់) / 5

[4] 44,784នាក់ = (42,284នាក់ + 44,033នាក់ + 45,109នាក់ + 47,654នាក់ + 44,841នាក់) / 5

តារាងទី៥.លទ្ធផលសម្រេចបានអនុកម្មវិធី ២.១

| ល.រ | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | |
| ៣៥ | និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុកដែលទទួលរបបសន្តិសុខសង្គម[5] | នាក់ | ៩៦ ០៦៩ | ១០០ ៣៨៦ | ១០២ ៤១១ | ១០៥ ៦៦៣ | ១០១ ៣១៣ | |
| | និវត្តជនដែលទទួលរបបសោធន | នាក់ | ៥១ ៣៤៥ | ៥៤ ០២៨ | ៥៥ ១៩៣ | ៥៥ ៩៧៥ | ៥៤ ៧៩៥ | |
| | ជនបាត់បង់សម្បទាវិជ្ជាជីវៈដែលទទួលរបបសោធន | នាក់ | ២ ៤៤០ | ២ ៣២៥ | ២ ១០៩ | ២ ០៣៤ | ១ ៦៧៧ | |
| | អ្នកនៅក្នុងបន្ទុក | នាក់ | ៤២ ២៨៤ | ៤៤ ០៣៣ | ៤៥ ១០៩ | ៤៧ ៦៥៤ | ៤៤ ៨៤១ | |

(ប្រភព÷ បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល)

**បង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងគ្រួសារ**

- បានផ្តល់ប័ណ្ណថែទាំសុខភាព ៦៨ ៩២៣ប័ណ្ណ ជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ និងប័ណ្ណមូលនិធិសមធម៌ ៣៣ ០៧៩ប័ណ្ណ ជូនគ្រួសារពលី និងមរណៈ
- បានបញ្ចូលបន្ទុកអតីតយុទ្ធជនសរុបចំនួន ៦៩១នាក់ និងលុបបន្ទុកចំនួន ៩ ៦៨៦នាក់
- បានផ្តល់ប្រាក់បូជាសព ប្រាក់១លើកដំបូង និងប្រាក់ធានារ៉ាប់រងសង្គមជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជនសរុបចំនួន ៦ ៩៧២នាក់
- បានលុបអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជនសរុបចំនួន ១៤ ៣៤៨នាក់ និងទទួលស្គាល់អតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជនឡើងវិញ ១៥៦នាក់
- បានកែសម្រួលប្រាក់សោធនជូន ជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ រហូតមកដល់ឆ្នាំ ២០២១ ប្រាក់សោធនអប្បបរមាត្រូវបានដំឡើងដល់ ៦៤០ ០០០រ/ខែ។ ក្នុងរយៈពេល៥ឆ្នាំនេះ អតីតយុទ្ធជននិងគ្រួសារប្រមាណ ៩៣ ៤៨៤នាក់[6] និងអ្នកនៅក្នុងបន្ទុក ១៣៨ ៦០៤នាក់[7] កំពុងទទួលរបបសន្តិសុខសង្គម តាមប្រព័ន្ធធនាគារ។

តារាងទី៦.លទ្ធផលសម្រេចបានអនុកម្មវិធី ២.២

| ល.រ | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | |
| ៣៦ | អតីតយុទ្ធជនដែលកំពុងទទួលរបបសន្តិសុខសង្គម[8] | នាក់ | ៨៦ ៥១៧ | ៨៨ ៥២៦ | ៩១ ៣១៩ | ៩៨ ៥៧៩ | ១០២ ៦៦៨ | |
| | និវត្តជនដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ២៦ ៤៧៩ | ២៧ ១០១ | ២៨ ៣៣៨ | ៣៣ ៣៨៨ | ៣៦ ៦៥៧ | |
| | ជនបាត់បង់សមត្ថភាពការងារដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ១ ៥៨៣ | ១ ៥៦៤ | ១ ៥២៧ | ១ ៤៥៩ | ១ ៤៨៣ | |
| | ជនពិការដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ២៦ ៥០១ | ២៧ ២០៥ | ២៧ ៤៣៧ | ២៨ ៣២៧ | ២៨ ៥៨៤ | |
| | ជនពលីដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ២៥ ៦៤៥ | ២៥ ៧៣២ | ២៦ ២៦៧ | ២៦ ៧៤៣ | ២៦ ៧៨៩ | |
| | ជនមរណៈដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ៦ ៣០៩ | ៦ ៩២៤ | ៧ ៧៥០ | ៨ ៦២២ | ៩ ១៥៥ | |
| | អ្នកនៅក្នុងបន្ទុកអតីតយុទ្ធជន | នាក់ | ១៣២ ៤៦៧ | ១៣០ ៤៤១ | ១៣៥ ៣៨៨ | ១៤៦ ០២៤ | ១៤៨ ៦៩៩ | |

[5] RID: Retiree Invalid people Database

[6] 93,484នាក់= (86,517នាក់ + 88,526នាក់ + 91,319នាក់ + 98,388នាក់ +102,668នាក់)/5

[7] 138,604នាក់= (132,467នាក់ + 130,441នាក់ + 135,388នាក់ + 146,024នាក់ +148,699នាក់)/5

[8] VID: Veterans Information Database

(ប្រភព÷ បេឡាជាតិអតីតយុទ្ធជន)

**បន្តនិរន្តរភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ**

- មូលនិធិជនពិការបានសហការជាមួយអង្គការដៃគូ ផ្តល់សេវាស្តារលទ្ធភាពពលកម្មប្រកបដោយគុណភាពដោយឥតគិតថ្លៃជូនជនពិការ ៣៧៨ ៨៦៨នាក់ ក្នុងនោះ សេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ ២៦៧ ៣៧៣នាក់ និងស្តារលទ្ធភាពពលកម្មកាយសម្បទាបាន ១១១ ៤៩៥នាក់។ ទន្ទឹមនេះ ជនពិការដែលមកទទួលសេវាពីមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម បានទទួលការឧបត្ថម្ភជាប្រាក់អាហារ និងថ្លៃធ្វើដំណើរទៅមកផងដែរ។ ក្រៅពីការផ្តល់សេវានៅតាមមណ្ឌលស្តារលទ្ធភាពពលកម្ម មូលនិធិជនពិការក៏បានផ្តល់សេវាសហគមន៍ជូនជនពិការ ដូចជា ការជួសជុលឧបករណ៍សិប្បនិម្មិតនិងរណប ការសម្របសម្រួលជូនជនពិការទៅទទួលសេវាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបញ្ជូនទៅសេវាសុខាភិបាលសរុបចំនួន ៣៨ ៧៣៨នាក់
- បានផ្តល់ប្រាក់ឧបត្ថម្ភរបបគោលនយោបាយសម្រាប់ពិនិត្យ និងថែទាំសុខភាព ជូនដល់ជនពិការក្រីក្រនៅតាមសហគមន៍បាន ២៩ ២១១នាក់ ដោយម្នាក់ៗទទួលបានថវិកា៣០.០០០៛
- បានសាងសង់ផ្ទះជូនគ្រួសារជនពិការក្រីក្រចំនួន ២៩ខ្នង និងបានផ្តល់កញ្ចប់អំណោយសប្បុរសធម៌របស់មូលនិធិជនពិការជូនជនពិការក្រីក្រសរុបចំនួន ២ ៣៥២នាក់
- បានទទួលប្រាក់ភាគទានដោយស្ម័គ្រចិត្តពីការមិនបានអនុវត្តតាមអត្រាកំណត់នៃការជ្រើសរើសជនពិការចូលបម្រើការងារពីក្រុមហ៊ុន និងរោងចក្រ សរុបចំនួន ២១៣ ២៥២ ៧២៩៛ និងទទួលបានប្រាក់ពីហិបប្រាក់វិភាគទានសប្បុរសធម៌មូលនិធិជនពិការសរុបចំនួន ៨១០ ០៦៩ ៤០០៛។

**តារាងទី៧.លទ្ធផលសម្រេចបានអនុកម្មវិធីទី២.៣**

| ល.រ | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | |
| ២៤ | ជនពិការដែលទទួលបានសេវាស្តារលទ្ធភាពពលកម្មកាយសម្បទានៅតាមមជ្ឈមណ្ឌល[9] | នាក់ | ២៦ ៣២៥ | ២៨ ០៤៥ | ២៦ ៣១០ | ១៨១៩៨ | ១២ ៦១៧ | ១១១ ៤៩៥ |
| ២៥ | ជនពិការដែលទទួលបានសេវាស្តារលទ្ធភាពពលកម្មនៅសហគមន៍ | នាក់ | ៨ ០៥១ | ១១ ៨៨៦ | ៩ ៨៨៩ | ៥ ១៣៩ | ៣ ៧៧៣ | ៣៨ ៧៣៨ |
| ២៦ | ជនពិការក្រីក្រទទួលបានរបបគោលនយោបាយឧបត្ថម្ភសេវាស្តារនិងពិនិត្យថែទាំសុខភាព | នាក់ | ៥ ១៣០ | ២ ៦៤៤ | ៥ ២៨៧ | ៦ ៨៩៨ | ៩ ២៥២ | ៩២ ២១១ |
| ៣១ | ជនពិការទទួលបានសេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ[10] | នាក់ | ៨២ ៥៩៦ | ៦០ ៤០០ | ៥៩ ០៦៣ | ៤៤ ៦១៣ | ២០ ៧០១ | ២៦៧ ៣៧៣ |

(ប្រភព÷ មូលនិធិជនពិការ)

**កម្មវិធីទី៣៖ ពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍភាពជាដៃគូ**

**ពង្រឹងសមត្ថភាពស្ថាប័ន និងភាពជាដៃគូ**

- បានចុះអធិការកិច្ច និងសវនកម្ម ដើម្បីពិនិត្យ កែលម្អការបំពេញមុខងារ តួនាទី របៀបរបបការងារ ការដោះស្រាយជម្លោះ ការគ្រប់គ្រងចំណាយថវិការដ្ឋ និងទ្រព្យសម្បត្តិរដ្ឋ នៅតាមមន្ទីរ ស.អ.យ. រាជធានី ខេត្ត សំដៅលើកកម្ពស់គណនេយ្យភាព តម្លាភាព ប្រសិទ្ធភាពនៃការផ្តល់សេវាសង្គមកិច្ចជូនជនរងគ្រោះ និងងាយរងគ្រោះគ្រប់ប្រភេទ
- បានបង្រួមប្រព័ន្ធនៃការផ្តល់សេវារដ្ឋបាល សេវាតម្រូវការ និងសេវាសំណូមពរតាមច្រកចេញចូលតែមួយ កាត់បន្ថយភាពយឺតយ៉ាវ គ្រប់គ្រង និងរក្សាបាននូវការសម្ងាត់ប្រកបដោយភាពគត់ហ្មត់ ស្របតាមកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ។ បានលើកទឹកចិត្តមន្ត្រីរាជការតាមរយៈការបណ្តុះបណ្តាលពង្រឹង

[9] PMS4: Patient Management System version 4
[10] PMS4: Patient Management System version 4

សមត្ថភាព ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ និងការបើកផ្តល់បៀវត្សទាំងពីរលើកបានទាន់ពេលវេលា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល

- បានពង្រឹងការងារផែនការ និងផ្សព្វផ្សាយ តាមរយៈ ការរៀបចំរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ ផែនការសកម្មភាពបីឆ្នាំរំកិល ២០២២-២០២៤ ផែនការសកម្មភាពអនុវត្តគោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០ និងកម្រងសេវាសាធារណៈរបស់ក្រសួង ដែលមានសេវាជាអាទិភាពសរុបចំនួន ២២សេវា
- បានអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងកម្មវិធីអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ៣៤អនក្រ.បក ចុះថ្ងៃទី ០៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីការប្រគល់មុខងារ "ការគ្រប់គ្រងមណ្ឌលថែទាំកុមារកំព្រារបស់រដ្ឋ" ឱ្យទៅរដ្ឋបាលរាជធានី ខេត្ត "ការធ្វើអធិការមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល" ឱ្យទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមុខងារ "ការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅសហគមន៍" ឱ្យ រដ្ឋបាលរាជធានី និងរដ្ឋបាលឃុំ សង្កាត់ ដោយក្នុងនោះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានផ្ទេរមន្ត្រីចំនួន ៥៦នាក់ និងផ្ទេរអចលនទ្រព្យ រួមមាន អគារ សម្ភារអចលនទ្រព្យមួយចំនួនទៀត ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត លើកលែងតែការផ្ទេរការគ្រប់គ្រងដីរបស់មណ្ឌលថែទាំកុមារទាំង ២១ កន្លែង នៃរាជធានីខេត្តទាំង ១៨ កំពុងស្ថិតក្នុងដំណើរការផ្ទេរជាជំហានៗ
- បានអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការគ្រប់គ្រងការបើកផ្តល់បានត្រឹមត្រូវនិងទាន់ពេលវេលា។ ការគ្រប់គ្រងសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងការបែងចែកសម្ភារប្រកបដោយស័ក្តិសិទ្ធភាព គណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព និងបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ
- ក្រសួងបានលើកទឹកចិត្ត និងសហប្រតិបត្តិការជាមួយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស និងដៃគូអភិវឌ្ឍន៍នានា ក្នុងស្មារតីសាមគ្គីធម៌ និងកៀរគរប្រភពធនធានទាំងសម្ភារ ថវិកា និងបច្ចេកទេស បម្រើឱ្យសំណូមពររបស់ជនរងគ្រោះ និងងាយរងគ្រោះគ្រប់ប្រភេទក្នុងសង្គម ជាអាទិ៍ បានចុះកិច្ចព្រមព្រៀងគម្រោងការជាមួយអង្គការ ១៤៩អង្គការ ដែលមានថវិកាគម្រោងសរុបចំនួន ៣២១ ៩៦៨ ៤៤៩.៥០ដុល្លារអាម៉េរិក។ ទន្ទឹមនេះ ក៏បានធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធក្នុងក្របខ័ណ្ឌទ្វេភាគី កម្ពុជា-ថៃ ពាក់ព័ន្ធនឹងការសាងសង់មជ្ឈមណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលគម្រោងនេះនឹងចាប់ផ្តើមសាងសង់ក្នុងត្រីមាសទី១ នៃឆ្នាំ២០២២ កម្ពុជា-វៀតណាមពាក់ព័ន្ធនឹងការផ្តល់ថវិកាដោយភាគីវៀតណាម ដើម្បីសាងសង់អគារចំនួន ០៤ នៅក្នុង មជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍កែវផុស ខេត្តព្រះសីហនុ។ ក្នុងក្របខណ្ឌតំបន់អាស៊ាន ពាក់ព័ន្ធនឹងវិស័យសុខុមាលភាពសង្គម និងការអភិវឌ្ឍ រួមមាន សេចក្តីថ្លែងការរួម ស្តីពីការលើកកម្ពស់សិទ្ធិស្ត្រី សន្តិភាព និងសន្តិសុខនៅតំបន់អាស៊ាន ផែនការមេអាស៊ានឆ្នាំ២០២៥៖ការបញ្ជ្រាបសិទ្ធិជនមានពិការភាព សេចក្តីប្រកាសអាស៊ាន ស្តីពីសិទ្ធិកុមារក្នុងបរិបទនៃការធ្វើទេសន្តរប្រវេសន៍ សេចក្តីប្រកាសស្តីពីការការពារកុមារពីគ្រប់ទម្រង់នៃការកេងប្រវ័ញ្ចតាមប្រព័ន្ធអ៊ិនធឺណេត និងការរំលោភបំពាននៅអាស៊ាន សេចក្តីថ្លែងការណ៍រួម ស្តីពីការបញ្ជាក់ជាថ្មីនៃការប្តេជ្ញាចិត្តដើម្បីលើកកម្ពស់សិទ្ធិកុមារក្នុងតំបន់អាស៊ាន សេចក្តីថ្លែងការណ៍រួមនៃកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ាន ស្តីពីសុខុមាលភាពសង្គមនិងអភិវឌ្ឍន៍លើកទី១០ សេចក្តីថ្លែងការណ៍រួមនៃកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានបូកបី ស្តីពីសុខុមាលភាពសង្គម និងអភិវឌ្ឍន៍លើកទី៦ សេចក្តីថ្លែងការណ៍រួមនៃកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ាន ស្តីពីសុខុមាលភាពសង្គម និងអភិវឌ្ឍន៍ ស្តីពីការកាត់បន្ថយផលប៉ះពាល់ដោយកូវីដ-១៩ លើក្រុមជនងាយរងគ្រោះក្នុងអាស៊ាន រៀបចំវេទិកាកុមារអាស៊ានលើកទី៦ ស្តីពីផលប៉ះពាល់នៃកូវីដ-១៩ និងស្ថានភាពបច្ចុប្បន្នចំពោះកុមារ ក្របខ័ណ្ឌថ្នាក់តំបន់និងផែនការសកម្មភាពដើម្បីអនុវត្តសេចក្តីប្រកាសអាស៊ានស្តីពីការពង្រឹងកិច្ចគាំពារសង្គម សេចក្តីប្រកាសហាណូយ ស្តីពីការពង្រឹងការងារសង្គមឆ្ពោះទៅរកសហគមន៍អាស៊ាន ដែលមានភាពស្អិតរមួត និងមានការឆ្លើយតបរបាយការណ៍លើកទី២ ស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការមេអាស៊ានឆ្នាំ២០២៥៖ការបញ្ជ្រាបសិទ្ធិជនមានពិការភាពឆ្នាំ២០១៩-២០២០ ផែនការសកម្មភាពថ្នាក់តំបន់ដើម្បីអនុវត្តសេចក្តីប្រកាសកូឡាឡាំពួរ ស្តីពីមនុស្សចាស់៖ការផ្ត

ល់សិទ្ធិអំណាចដល់មនុស្សចាស់ក្នុងតំបន់អាស៊ាន និងក្របខ័ណ្ឌប្រតិបត្តិនៃពានរង្វាន់ការងារឆ្នើមលើវិស័យសុខុមាលភាពសង្គម និងអភិវឌ្ឍន៍អាស៊ាន ។

**អភិវឌ្ឍធនធានមនុស្ស**

- ក្រសួងបានពង្រឹង និងពង្រីកសកម្មភាពវិទ្យាស្ថានជាតិសង្គមកិច្ច សំដៅបណ្តុះបណ្តាលធនធានមនុស្ស សម្រាប់ស្ថាប័នរដ្ឋ វិស័យឯកជន និងអង្គការ សមាគម មិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសដែលពាក់ព័ន្ធនឹងការងារសង្គមកិច្ច។ វិទ្យាស្ថានបាននិងកំពុងបណ្តុះបណ្តាលនិស្សិតកម្រិតឧត្តមសិក្សាដែលសិក្សាលើជំនាញសង្គមកិច្ច ជំនាញសង្គមវិទ្យា ជំនាញកិច្ចគាំពារសង្គម ជំនាញវិស្វកម្មសិប្បនិម្មិតនិងរណប ជំនាញគ្រប់គ្រងសាធារណៈ ជំនាញរដ្ឋបាលសាធារណៈ ជំនាញគោលនយោបាយសង្គម ជំនាញគោលនយោបាយសាធារណៈ និងជំនាញអក្សរសាស្ត្រអង់គ្លេសសរុបចំនួន ៤៦៣នាក់ និស្សិតបរទេស ១៤នាក់។ និស្សិតដែលបានប្រឡងជាប់ជាស្ថាពរថ្នាក់បរិញ្ញាបត្រចំនួន ២៦៩នាក់ និស្សិតបរទេស ១០នាក់ និងសិក្ខាកាមដែលបានបញ្ចប់ការសិក្សាជំនាញផ្សេងៗរយៈពេលខ្លីចំនួន ៦២៨នាក់ និងបណ្តុះបណ្តាលជំនាញអ្នកជំនួយបច្ចេកទេសឧបករណ៍បច្ចេកទេសសិប្បនិម្មិតនិងរណបចំនួន ២៦នាក់។

**តារាងទី៨.លទ្ធផលសម្រេចបានអនុកម្មវិធី ៣.២**

| ល.រ | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | |
| ៣៧ | និស្សិតដែលបានចុះឈ្មោះចូលរៀនឆ្នាំទី១ | នាក់ | ២២១ | ១៦៧ | ៩៦ | ១៣២ | ៩២ | ៧០៨ |
| ៣៨ | និស្សិតដែលកំពុងសិក្សាកម្រិតបរិញ្ញាបត្រ | នាក់ | ៤៣៣ | ៤៨៩ | ៤០០ | ៤៤១ | ៤៦៣ | |
| ៣៩ | និស្សិតដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ | នាក់ | ៨៨ | ២០ | ៩១ | ៧០ | - | ២៦៩ |
| ៤០ | សិក្ខាកាមដែលបានបញ្ចប់ការសិក្សាកម្រិតវិញ្ញាបនបត្រ | នាក់ | ៦២ | ៧៥ | ២២៥ | ២០៨ | ៥៨ | ៦២៨ |

(ប្រភព៖ ទិន្នន័យរដ្ឋបាលវិទ្យាស្ថានជាតិសង្គមកិច្ច)

បញ្ហាប្រឈម៖

- ការយល់ដឹងអំពីប្រព័ន្ធគាំពារសង្គម ដូចជាអត្ថប្រយោជន៍ និងកាតព្វកិច្ចក្នុងការចូលរួមរបស់ប្រជាជននៅក្នុងរបប ឬកម្មវិធីនីមួយៗនៅមានកម្រិត។ ការពង្រឹងសមត្ថភាពមន្ត្រីក៏ជាតម្រូវការចាំបាច់ដែលត្រូវបង្កើនឱ្យស្របតាមស្ថានភាព និងតម្រូវការជាក់ស្តែង
- ការរីករាលដាលនៃជំងឺកូវីដ១៩ បានបង្កមហន្តរាយយ៉ាងធ្ងន់ធ្ងរដល់សុខភាពសាធារណៈ សង្គម សេដ្ឋកិច្ច និងជីវភាពប្រជាជន។ ប្រជាជនជាច្រើនអត់ការងារធ្វើ បាត់បង់ចំណូល ធ្លាក់ទៅក្នុងភាពក្រីក្រ ដែលជាបន្ទុកយ៉ាងធ្ងន់សម្រាប់រាជរដ្ឋាភិបាលក្នុងការស្តារ និងលើកស្ទួយជីវភាពរស់នៅរបស់ប្រជាជន។ ដោយឡែក សម្រាប់ឆ្នាំ២០២០ ដោយសារការីករាលនៃជំងឺកូវីដ-១៩ បានបណ្តាលឱ្យសេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថានឹងអាចធ្លាក់ចុះដល់ -១,៩%។ ការធ្លាក់ចុះនៃសេដ្ឋកិច្ចយ៉ាងខ្លាំងនេះត្រូវបានរំពឹងថា ផលិតផលសរុបសម្រាប់មនុស្សម្នាក់ធ្លាក់ចុះពី ១ ៧០០ដុល្លារអាម៉េរិក/២០១៩ មក១ ៦៨៣ដុល្លារអាម៉េរិក/២០២០ អត្រាភាពក្រីក្រ និងអត្រាភាពគ្មានការងារធ្វើបានកើនឡើង។
- នៅកម្ពុជាមិនទាន់មានទិន្នន័យជាក់លាក់អំពីកុមារកំព្រា កុមារងាយរងគ្រោះ និងកុមារពិការទេ។ ម៉្យាងវិញទៀត កុមារពិការ គឺជាក្រុមដែលងាយរងគ្រោះ ហើយលទ្ធភាពក្នុងការទទួលបានសេវាកម្មនានាពីសង្គមនៅមានកម្រិត ពួកគេខ្លះប្រឈមនឹងការរើសអើង
- ទោះជា រាជរដ្ឋាភិបាល និងក្រសួងបានខិតខំប្រឹងប្រែងផ្សព្វផ្សាយច្បាប់ ស្តីពីយុត្តិធម៌អនីតិជន និងច្បាប់ ស្តីពីសុំកូនអន្តរប្រទេសយ៉ាងណាក៏ដោយ ក៏យើងសង្កេតឃើញថា មហាជននៅមិនទាន់មានការយល់ដឹងបានទូលំទូលាយអំពីច្បាប់ទាំងពីរនេះដែរ។ ការជួយដល់អនីតិជនទំនាស់នឹងច្បាប់នៅមានកម្រិត មណ្ឌលយុវនីតិសម្បទាទើបចាប់ផ្តើមកសាងសម្រាប់ទទួលអនីតិជនទំនាស់នឹងច្បាប់

- ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន បានទទួលសេវាព្យាបាលនិងស្តារនីតិសម្បទា រាប់ពាន់នាក់ក្នុងមួយឆ្នាំតាមរយៈមណ្ឌលព្យាបាល និងស្តារនីតិសម្បទា ព្រមទាំងធ្វើសមាហរណកម្មទៅគ្រួសារ និងសហគមន៍វិញ ប៉ុន្តែ ក្រសួងមិនដឹងថាតើជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនប៉ុន្មាននាក់លាប់ត្រឡប់ទៅប្រើប្រាស់គ្រឿងញៀនសារជាថ្មី ដោយសារកង្វះ/គ្មានកិច្ចសហការពីឪពុកម្តាយ ឬអាណាព្យាបាលរបស់ជនរងគ្រោះ
- មជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ បាននិងកំពុងទទួលជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនឱ្យស្នាក់នៅ ព្យាបាល បន្សាប និងស្តារនីតិសម្បទា ខណៈដែលមជ្ឈមណ្ឌលនេះកំពុងសាងសង់នៅឡើយ ហេដ្ឋារចនាសម្ព័ន្ធមួយចំនួនមិនទាន់រួចរាល់ មិនទាន់មានការចាត់តាំងបុគ្គលិកគ្រូពេទ្យមកបម្រើការងារនៅមជ្ឈមណ្ឌល លើសពីនេះទៀតអនុក្រឹត្យ ស្តីពីការបង្កើតមជ្ឈមណ្ឌលជាតិនេះមិនទាន់អនុម័តដែលនាំឱ្យមានការលំបាកក្នុងការកំណត់តួនាទី ភារកិច្ចរបស់អង្គភាពចំណុះ
- ជនពិការ គឺជាជនក្រីក្របំផុតក្នុងចំណោមជនក្រីក្រក្នុងសហគមន៍ ជាជនភ្ជាប់មកជាមួយនូវបញ្ហាប្រឈមជាអន្តរកម្ម ផ្នែកពិការភាព និងឧបស័គ្គទាំងឡាយរួមទាំងអកប្បកិរិយា និងបរិយាកាសជុំវិញ ដែលរារាំងពួកគាត់មិនឲ្យចូលរួមក្នុងសង្គមបានពេញលេញនិងស្មើភាព។ ជារឿយៗពួកគាត់ជួបការលំបាក ទាំងផ្នែកកាយសម្បទា ផ្លូវចិត្ត និងហិរញ្ញវត្ថុ ដែលទាំងនេះជារបាំងសម្រាប់ពួកគាត់ទទួលបានសេវាផ្សេងៗរួមមានសេវាសុខាភិបាល អប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ ។ ជាងនេះទៀត ពួកគាត់ភាគច្រើនមានការអប់រំទាប ការយល់ដឹងនៅមានកម្រិត ជាកត្តាពិបាកក្នុងការចាប់យកជំនាញដែលទទួលបានប្រាក់កម្រៃខ្ពស់ ព្រមទាំងបានកម្រិតពួកគាត់មិនអាចប្រកួតប្រជែងក្នុងទីផ្សារសេរី និងចាញ់ប្រៀបជាមួយអ្នកដទៃក្នុងការទទួលបានចំណែកនៃការបង្កើនផលិតភាពក្នុងវិស័យសេដ្ឋកិច្ច ឬមិនអាចទទួលបានអត្ថប្រយោជន៍ពីការរីកចម្រើនសេដ្ឋកិច្ចជាតិ
- មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មភាគច្រើនទទួលបានហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ នៅពេលដែលដៃគូអភិវឌ្ឍន៍បន្ថយ ឬបញ្ឈប់ការគាំទ្រ ធ្វើឱ្យមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មជួបបញ្ហាហិរញ្ញវត្ថុដែលនាំឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ផលិតភាព និងគុណភាពនៃសេវា។ ការសុំឈប់ពីការងាររបស់បុគ្គលិកបច្ចេកទេសធ្វើឱ្យមជ្ឈមណ្ឌលមួយចំនួនកំពុងខ្វះអ្នកបច្ចេកទេសផ្តល់សេវាដល់ជនពិការ ដោយសារបុគ្គលិកទាំងនេះមិនមានក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងប្រាក់ឧបត្ថម្ភប្រចាំខែនៅមានកម្រិត
- ពិតមែនតែចំនួនជនពិការដែលចូលបម្រើការងារក្នុងវិស័យឯកជនមានការកើនឡើង ប៉ុន្តែចំនួននេះនៅមិនទាន់អនុវត្តបានតាមអត្រាកំណត់សម្រាប់វិស័យឯកជន ដែលទាមទារឱ្យអ្នកដែលមានចំណែកពាក់ព័ន្ធទាំងអស់ត្រូវចូលរួមអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ
- ការយល់ដឹង និងលទ្ធភាពទទួលព័ត៌មានអំពី ការបណ្តុះបណ្តាលវិជ្ជាជីវៈ សេវាស្តារលទ្ធភាពពលកម្ម និងសេវាផ្សេងៗទៀតរបស់ជនពិការនៅមានកម្រិតទោះបីជាមានការផ្សព្វផ្សាយយ៉ាងណាក៏ដោយ ដែលធ្វើឱ្យជនពិការបាត់បង់ឱកាសក្នុងការទទួលនូវការបណ្តុះបណ្តាល និងអត្ថប្រយោជន៍ផ្សេងៗពីរដ្ឋ
- និរន្តរភាពសមាគមមនុស្សចាស់មិនទាន់មានភាពច្បាស់លាស់និងប្រាកដនិយម ដោយសារកង្វះថវិកា និងបច្ចេកទេសដើម្បីជួយទ្រទ្រង់ដល់ដំណើរការសមាគម
- ការកើនឡើងនូវចំនួនមនុស្សវ័យចាស់ដែលមានអាយុ៦០ឆ្នាំឡើង នៅឆ្នាំ២០១៣ មនុស្សវ័យចាស់មាន ៧.២% ប្រមាណ ១ ២០០ ០០០នាក់ នៃប្រជាជនសរុប ១៥លាននាក់ នៅឆ្នាំ២០១៩ មាន ៨.៩% ប្រមាណ ១ ៣៨៤ ១៤៧នាក់ នៃប្រជាជនសរុប ១៥ ៥៥២ ២១១នាក់ ហើយត្រូវបានព្យាករណ៍ថា នឹងកើនឡើងរហូតដល់ ១១% ប្រមាណ ១ ៩៩០ ០០០នាក់ នៃប្រជាជនសរុប ១៨លាននាក់ នៅឆ្នាំ ២០៣០។ ពិតមែនតែមនុស្សវ័យចាស់កម្ពុជាមានអាយុកាន់តែវែង ហើយរស់នៅក្នុងជីវិតដែលមានសុខភាពល្អជាងមុន ប៉ុន្តែ ពួកគាត់ប្រឈមមុខកាន់តែច្រើនទៅនឹងកត្តាផ្នែកសង្គម សេដ្ឋកិច្ច ស្ថានភាពសុខភាព
- ការចំណាយលើផ្នែកសុខភាពមានការកើនឡើង និងអសន្តិសុខផ្នែកហិរញ្ញវត្ថុក៏មានការកើនឡើងទៅតាមអាយុ ដែលអាចនាំឱ្យមនុស្សចាស់ធ្លាក់ចូលទៅក្នុងភាពក្រីក្រ នៅពេលដែលពួកគាត់មានអាយុកាន់តែច្រើន។ មនុស្សចាស់ដែលជួបប្រទះអសន្តិសុខហិរញ្ញវត្ថុ និងមិនមានសមត្ថភាពអាចធ្វើការបាន ចាំបាច់ត្រូវស្ថិតក្រោមគម្រោងគាំពារសង្គមនិងសុខុមាលភាព។

## II-ទិសដៅគោលនយោបាយ

ដើម្បីថែរក្សាសមិទ្ធផលដែលក្រសួងសម្រេចបានកន្លងមក និងចូលរួមអនុវត្តឱ្យបានពេញលេញនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០៣០ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ត្រង់មុំទី៣ និងទី៤នៃចតុកោណទី១ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផ.យ.អ.ជ. ជំពូក៤ លេខ៣.៣ និង៣.៤ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានឹងបន្តអនុវត្តកម្មវិធី ០៣ អនុកម្មវិធីមួយចំនួនជាអាទិភាព រួមទាំងសកម្មភាព ដូចខាងក្រោម៖

### កម្មវិធីទី១៖ ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គមការអភិវឌ្ឍសុខុមាលភាពជនរងគ្រោះ និងជនងាយរងគ្រោះ និងកិច្ចការគ្រួសារ

- បន្តរៀបចំកម្មវិធីជំនួយសង្គមជាកញ្ចប់គ្រួសារ តាមរយៈ ការធ្វើសមាហរណកម្មកម្មវិធីជំនួយសង្គមបញ្ចូលគ្នា រួមមាន កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម ២ឆ្នាំ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនពិការ កម្មវិធីឧបត្ថម្ភមនុស្សវ័យចាស់ និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនសិស្សក្រីក្រនៅតាមភូមិសិក្សា និងបន្តរៀបចំប្រព័ន្ធគ្រប់គ្រង និងការឆ្លើយតបគ្រោះអាសន្នក្នុងការផ្តល់ជំនួយសង្គម
- សិក្សា និងរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យជនចំណាកស្រុក សំដៅផ្តល់សេវាឆ្លើយតបបន្ទាន់សម្រាប់ជនចំណាកស្រុក និងបង្ការទប់ស្កាត់ជនអនាថា
- ដោះស្រាយបញ្ហាជនអនាថាតាមរយៈការផ្តល់សេវាអប់រំផ្លូវចិត្ត ពិគ្រោះយោបល់ ការថែទាំសុខភាព ស្តារនីតិសម្បទា បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ បង្កឱកាសស្តារជីវភាពនិងធ្វើសមាហរណកម្មទៅក្នុងសង្គមដោយឈរលើគោលការណ៍គោរពសិទ្ធិមនុស្ស។ ទប់ស្កាត់ការធ្វើចំណាកស្រុកខុសច្បាប់ តាមរយៈ ការផ្សព្វផ្សាយអប់រំ ការបញ្ជ្រាបការយល់ដឹងស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ការពង្រឹងប្រសិទ្ធភាពគ្រប់គ្រងមជ្ឈមណ្ឌលសំចតសង្គមកិច្ច និងការទទួលជនវិបល្លាសស្មារតីឱ្យស្នាក់នៅក្នុងមជ្ឈមណ្ឌលព្យាបាលនិងថែទាំជនវិបល្លាសស្មារតី
- ផ្តល់សេវាថែទាំគាំទ្រ និងសង្គ្រោះជនរងគ្រោះ និងជនរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗ
- អនុវត្តកម្មវិធីអភិវឌ្ឍគ្រួសារល្អ ការចិញ្ចឹមកូនបែបវិជ្ជមាន ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ដោយប្រមូលផ្តុំលើ ការសិក្សានិងរៀបចំគោលនយោបាយជាតិ ស្តីពីការគាំពារគ្រួសារ ការរៀបចំទិវាអន្តរជាតិ ស្តីពីគ្រួសារ ១៥ឧសភា ការបញ្ជ្រាបការងារយេនឌ័រ និងអនុសញ្ញា ស៊ី-ដ ទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ
- សិក្សាដាក់ឱ្យដំណើរការការចុះបញ្ជីកម្លាំងសេវាសង្គម ដើម្បីពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាដល់ជនរងគ្រោះ និងងាយរងគ្រោះគ្រប់ប្រភេទ ដោយប្រមូលផ្តុំលើការរៀបចំអនុក្រឹត្យស្តីពីក្រមសីលធម៌សម្រាប់កម្លាំសេវាសង្គម ផែនការយុទ្ធសាស្ត្រជាតិស្តីពីកម្លាំងសេវាសង្គមនៅកម្ពុជា និងលិខិតគតិយុត្តនានា
- ផ្តល់កិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទ ដោយប្រមូលផ្តុំលើ ការផ្តល់សេវាការពារផ្លូវច្បាប់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភផ្លូវភេទ ការប្រឹក្សាយោបល់ ការបញ្ជូនទៅស្តារនីតិសម្បទា និងការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងរំលោភផ្លូវភេទ មុនធ្វើសមាហរណកម្ម និងការតាមដានបន្ត
- ទទួល និងធ្វើមាតុភូមិនិវត្តជនរងគ្រោះដោយអំពើជួញដូរមនុស្សដោយគ្មានការមាក់ងាយ និងរើសអើង ដោយប្រមូលផ្តុំលើ ការបង្កើតនិងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យជនរងគ្រោះដោយអំពើជួញដូរមនុស្ស (Database Management System for Victims of Human Trafficking) ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការជួយគាំពារ និងស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការដាក់ឱ្យដំណើរការមជ្ឈមណ្ឌលសំចតប៉ោយប៉ែតសម្រាប់ទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្សឆ្លងដែន។

### ការអភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា

- បន្តពង្រឹងប្រព័ន្ធ និងគុណភាពសេវាកិច្ចការពារកុមារ ដោយប្រមូលផ្តុំលើការបង្កើតនិងដាក់ឱ្យដំណើរការប្រព័ន្ធទិន្នន័យថ្នាក់ជាតិដើម្បីគ្រប់គ្រងទិន្នន័យកុមាររងគ្រោះនិងងាយរងគ្រោះ

- ការលើកកម្ពស់សមត្ថភាព និងគុណភាពនៃការគ្រប់គ្រងមណ្ឌលថែទាំកុមារ ដោយផ្តោតលើគុណភាពសេវាការគ្រប់គ្រងករណី ការធ្វើអធិការកិច្ចកន្លែង ឬមណ្ឌលថែទាំកុមារ និងការថែទាំកុមារតាមសហគមន៍ឱ្យស្របតាមគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ
- បន្តលើកកម្ពស់សេវាថែទាំ និងគុណភាពការថែទាំកុមារតាមគ្រួសារនិងសហគមន៍ ដោយប្រមូលផ្តុំលើ ការពង្រឹងពង្រីកកម្មវិធីការបង្រួបបង្រួមគ្រួសារ ការបង្វែរ និងសមាហរណកម្មកុមារពីមណ្ឌលទៅជាការថែទាំនៅតាមគ្រួសារនិងសហមគន៍ រួមទាំងការថែទាំដោយឪពុកម្តាយធម៌ ការថែទាំដោយសាច់ញាតិ និងសុំកូនក្នុងប្រទេស និងតាមដានការអនុវត្តមុខងារដែលបានផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួល និងតាមដានការអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ
- តាមដានការអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ
- ពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងរបាយការណ៍ស្តីពីស្ថានភាពកុមារ ដោយប្រមូលផ្តុំលើ ការអនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ផែនការអនុវត្តគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ ផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ឆ្នាំ២០១៩-២០២៥ សំដៅលើកកម្ពស់សិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ
- ជំរុញនិងលើកកម្ពស់ការអនុវត្តសិទ្ធិកុមារ តាមរយៈ ការផ្សព្វផ្សាយអនុសញ្ញាស្តីពីសិទ្ធិកុមារ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសិទ្ធិ និងការការពារកុមារ ការពង្រឹងសមត្ថភាពមន្ត្រីរដ្ឋាភិបាលនិងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលឱ្យបានទូលំទូលាយ និងច្បាប់ស្តីពីកិច្ចការពារកុមារនៅកម្ពុជា
- អនុវត្តកាតព្វកិច្ចក្នុងនាមជាសមាជិកនៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ តាមរយៈការរៀបចំរបាយការណ៍ជាតិ ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ របាយការណ៍ស្តីពីការអនុវត្តពិធីសារបន្ថែម និងការរៀបចំទិវាកុមារអន្តរជាតិ ១មិថុនា និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា
- បន្តអនុវត្តគម្រោង "យុទ្ធនាការផ្សព្វផ្សាយ ស្តីពីផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុមកលើស្ត្រី និងកុមារក្នុងតំបន់អាស៊ាន"
- អនុវត្តការងារសុំកូនអន្តរប្រទេសដោយធានាឧត្តមប្រយោជន៍ និងការពារសិទ្ធិជាមូលដ្ឋានរបស់កុមារ ដោយប្រមូលផ្តុំលើការផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលមានវិជ្ជាជីវៈ និងក្រមសីលធម៌ក្នុងការធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស ការផ្សព្វផ្សាយនិងការបណ្តុះបណ្តាល ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ស្តីពីសុំកូនអន្តរប្រទេសដល់អ្នកពាក់ព័ន្ធ
- ផ្តល់សេវាស្តារនីតិសម្បទាអនីតិជនដែលទំនាស់នឹងច្បាប់ ដោយប្រមូលផ្តុំលើ ការសាងសង់និងដាក់ឱ្យដំណើរការមណ្ឌលយុវនីតិសម្បទា រៀបចំកម្មវិធីបណ្តុះបណ្តាលបំណិនជីវិតនិងជំនាញវិជ្ជាជីវៈដល់អនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា ការផ្សព្វផ្សាយ អប់រំកុមារ យុវជន ទប់ស្កាត់បាតុភាពអសកម្មនានាក្នុងសង្គម
- រៀបចំនិងដាក់ឱ្យអនុវត្តនូវគោលការណ៍សម្រាប់ការអនុវត្តផែនការបង្វែរ និងរចនាសម្ព័ន្ធភ្នាក់ងារសង្គមកិច្ចពាក់ព័ន្ធនឹងយុត្តិធម៌អនីតិជន ព្រមទាំងការផ្តល់សេវាសង្គមកិច្ចគាំពារដល់កុមារតាមម្តាយក្នុងពន្ធនាគារ
- ផ្តល់ស្តារនីតិសម្បទាជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន ដោយប្រមូលផ្តុំលើ ការទទួលព្យាបាល បន្សាប ស្តារនីតិសម្បទា និងបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀននៅក្នុងមណ្ឌល និងលើកទឹកចិត្តការព្យាបាលនិងស្តារនីតិសម្បទាជនរងគ្រោះដែលប្រើប្រាស់បំពានសារធាតុញៀននៅតាមសហគមន៍ ដោយមានការចូលរួមទទួលខុសត្រូវ របស់ឪពុកម្តាយ និងសាច់ញាតិ។

**ការអភិវឌ្ឍសុខុមាលភាពជនពិការ**

- បង្កើនប្រសិទ្ធភាពផ្តល់សេវាសុខុមាលភាពជនពិការ និងលើកកម្ពស់សិទ្ធិជនពិការ ដោយប្រមូលផ្តុំលើ ការរៀបចំប្រព័ន្ធទិន្នន័យគ្រប់គ្រងជនពិការឱ្យបានច្បាស់លាស់ បណ្តុះបណ្តាលវិជ្ជាជីវៈនិងបង្កើតមុខរបរដល់ជនពិការ សម្របសម្រួលនិងជំរុញឱ្យក្រសួង ស្ថាប័នរដ្ឋ និងសហគ្រាសឯកជនអនុវត្តកាតព្វកិច្ចទទួលជនពិការចូលបម្រើការងារ និងរៀបចំលក្ខណៈងាយស្រួល សម្រាប់ជនពិការបំលាស់ទី និងលើកទឹកចិត្តចលនាកីឡា សិល្បៈរបស់ជនពិការ

- ពង្រឹងការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិជនពិការ ច្បាប់ ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ផែនការយុទ្ធសាស្ត្រជាតិ ស្តីពីពិការភាព និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត តាមរយៈ ការរៀបចំនិងដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីពិការភាព ២០១៩-២០២៣ ការធ្វើវិសោធនកម្មច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ការផ្តល់សេវាផ្លូវច្បាប់សម្រាប់ជនពិការដោយសហការជាមួយស្ថាប័នតុលាការ មន្ត្រីយុត្តិធម៌ និងបុគ្គលិកពន្ធនាគារ ការរៀបចំរបាយការណ៍នៃការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការនិងពិធីសារបន្ថែម ការពង្រឹងយន្តការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិជនពិការ ការរៀបចំទិវាជនពិការជាតិ អន្តរជាតិ និងទិវាផ្សេងៗពាក់ព័ន្ធជនពិការ ការអនុវត្តស្តង់ដាអប្បបរមានៃការបង្កលក្ខណៈងាយស្រួលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត មធ្យោបាយធ្វើដំណើរនិងទំនាក់ទំនងសម្រាប់ជនពិការ ការបញ្ច្រាបការយល់ដឹងអំពីសមត្ថភាពបើកបរនិងផ្តល់ប័ណ្ណបើកបរសម្រាប់ជនពិការ និងការផ្សព្វផ្សាយលិខិត បទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងពិការភាព។

**អភិវឌ្ឍសុខុមាលភាពមនុស្សចាស់**

- ពង្រឹងសកម្មភាពសមាគមមនុស្សចាស់ តាមឃុំ សង្កាត់ ដោយប្រមូលផ្តុំលើ ការផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់សមាគមមនុស្សចាស់ ការពង្រឹងសមត្ថភាពគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់និងអនុគណៈកម្មាធិការដើម្បីមនុស្សចាស់ថ្នាក់រាជធានី ខេត្ត និងការកែសម្រួលលក្ខន្តិកៈសមាគមមនុស្សចាស់និងគោលការណ៍ណែនាំ ស្តីពីការបង្កើត និងគ្រប់គ្រងសមាគមមនុស្សចាស់
- ជំរុញអនុវត្តគោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០ តាមរយៈការរៀបចំនិងអនុវត្តផែនការសកម្មភាព ការរៀបចំលិខិតបទដ្ឋានគតិយុត្តការដាក់ឱ្យដំណើរការមជ្ឈមណ្ឌលជាតិគាំពារមនុស្សវ័យចាស់ សំដៅបណ្តុះបណ្តាលវិជ្ជាជីវៈថែទាំមនុស្សចាស់សម្រាប់អ្នកថែទាំ អ្នកធ្វើកិច្ចការសង្គម និងអ្នកស្ម័គ្រចិត្ត។

**ការអភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន**

- អភិវឌ្ឍសហគមន៍អតីតយុទ្ធជន ដោយប្រមូលផ្តុំលើ ការបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជនឃុំ សង្កាត់ និងការបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីនីតិវិធីប្រមូលទិន្នន័យពីស្ថានភាពជីវភាព និងតម្រូវការរបស់អតីតយុទ្ធជន និងគ្រួសារ នៅតាមឃុំ សង្កាត់ សំដៅកែលម្អ និងទ្រទ្រង់ជីវភាពអតីតយុទ្ធជន និងគ្រួសារ
- សម្របសម្រួលការងារសមាគមអតីតយុទ្ធជននៅថ្នាក់ឃុំ សង្កាត់ ដោយសហការយ៉ាងជិតស្និទ្ធជាមួយសមាគមអតីតយុទ្ធជនកម្ពុជា ដើម្បីពង្រឹងការអនុវត្តបេឡាមរណសង្គ្រោះ ការសាងសង់ផ្ទះ ការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន និងការរៀបចំទិវាអតីតយុទ្ធជនកម្ពុជា ២១មិថុនា នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## កម្មវិធីទី២៖ បង្កើនប្រសិទ្ធភាពប្រព័ន្ធសន្តិសុខសង្គម និងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ

**អភិវឌ្ឍសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលប្រកបដោយប្រសិទ្ធភាព**

- ផ្តល់របបសន្តិសុខសង្គមជូនសិទ្ធិវន្តនៃ ប.ជ.ស. តាមរយៈ ការបើកផ្តល់របបសន្តិសុខសង្គមជូននិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក បានទាន់ពេលវេលា និងការបង្កើតយន្តការសិក្សាស្រាវជ្រាវដើម្បីកាត់បន្ថយគម្លាតនៃរបបសោធនរបស់មន្ត្រីសាធារណៈ
- សហការជាមួយបេឡាជាតិរបបសន្តិសុខសង្គម ប.ស.ស. ដើម្បីផ្តល់សេវាធានារ៉ាប់រងសុខភាពសម្រាប់អតីតមន្ត្រីរាជការស៊ីវិល
- ពន្លឿនការបើកផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រួសារសពនិវត្តជន និងសពជនបាត់បង់សម្បទាវិជ្ជាជីវៈ និងបន្តផ្ទេរសិទ្ធិជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈដែលមានជំងឺមិនអាចទៅបើកប្រាក់សោធនប្រចាំខែនៅតាមធនាគារ។

**ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងគ្រួសារ**

- បង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន ដោយប្រមូលផ្តុំលើ ការបើកផ្តល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជននិងអ្នកនៅក្នុងបន្ទុក និងប្រាក់គោល

នយោបាយមរណភាពជូនដល់គ្រួសារអតីតយុទ្ធជនឱ្យបានទាន់ពេលវេលា ការធ្វើបច្ចុប្បន្នភាពអតីតយុទ្ធជន និងការចេញលិខិតផ្ទេរសិទ្ធិបើកប្រាក់របបសន្តិសុខសង្គមប្រចាំខែជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន

- បន្តកែសម្រួលរបបសន្តិសុខសង្គម តាមរយៈការកាត់បន្ថយគម្លាតនៃរបបសោធនរបស់នគរបាលជាតិ និងយោធិននៃកងយោធពលខេមរភូមិន្ទ និងការបង្កើនប្រាក់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងអ្នកនៅក្នុងបន្ទុក។

**ការបន្តនិរន្តរភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ**

- ផ្តល់សេវាស្តារលទ្ធភាពពលកម្មគ្រប់ប្រភេទជូនជនពិការ ដោយប្រមូលផ្តុំលើ ការផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទា ការផ្តល់សេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ ការផ្តល់សេវាតាមសហគមន៍សម្រាប់ជនពិការ និងការផលិតឧបករណ៍សិប្បនិម្មិត និងឈើច្រត់
- កៀរគរប្រភពធនធានថវិកាសម្រាប់និរន្តរភាពសេវាស្តារលទ្ធភាពពលកម្មជូនជនពិការ។
- បន្តអនុវត្តអនុវត្តការប្រមូលភាគទានប្រាក់ពិន័យអន្តរការណ៍ចំពោះស្ថាប័ននានា និងនីតិបុគ្គលដែលមិនបានបំពេញកាតព្វកិច្ច ដូចមានចែងក្នុងច្បាប់ ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ការពង្រីកការដាក់ហិបមូលនិធិជនពិការនៅតាមរាជធានី ខេត្ត ការវិនិយោគផ្សេងៗ និងការសហប្រតិបត្តិការជាមួយអង្គការដៃគូនានា
- ផ្តល់កម្រៃ ថ្លៃសេវាធ្វើដំណើរ និងអាហារដល់ជនពិការ ដែលមកទទួលសេវាព្យាបាលនៅតាមមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម និងអនុវត្តការបើកផ្តល់របបគោលនយោបាយថែទាំសុខភាពជូនជនពិការក្រីក្រនៅសហគមន៍។

**កម្មវិធីទី៣៖ ពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍភាពជាដៃគូ**

**ពង្រឹងសមត្ថភាពស្ថាប័ន និងភាពជាដៃគូ**

- ពង្រឹងសមត្ថភាពមន្ត្រីរាជការ និងបង្កើនប្រសិទ្ធភាពការងារ ដោយប្រមូលផ្តុំលើ ការពង្រឹងការគ្រប់គ្រងមន្ត្រីរាជការ ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រី តាមរយៈ ការអនុវត្តច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល បទបញ្ជាផ្ទៃក្នុង និងរបៀបរបបធ្វើការឱ្យបានហ្មត់ចត់
- លើកទឹកចិត្តមន្ត្រីគ្រប់លំដាប់ថ្នាក់ តាមរយៈការដំឡើង ឋានៈ តួនាទី ឋានន្តរស័ក្តិ ថ្នាក់ ប្រាក់បំណាច់មុខងារ និងប្រាក់បំណាច់ផ្សេងៗ
- ពង្រឹងការងារផែនការ និងផ្សព្វផ្សាយ តាមរយៈ ការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ ការពិនិត្យនិងវាយតម្លៃការអនុវត្តសកម្មភាពនិងលទ្ធផលការងាររបស់អង្គភាពចំណុះ និងមន្ទីរ ស.អ.យ. រាជធានី ខេត្ត ការផ្សព្វផ្សាយលទ្ធផលការងារដែលសម្រេចបាន និងការពង្រឹងប្រព័ន្ធស្ថិតិ
- បន្តអនុវត្តកម្មវិធីកំណែទម្រង់នានារបស់រដ្ឋ រួមមាន កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈ ការដាក់ឲ្យប្រើប្រាស់ពេញលេញមុខងារ FMIS ប្រព័ន្ធព្យាករណ៍សាច់ប្រាក់ CMS ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ SAMIS និងការដាក់ឲ្យប្រើប្រាស់នូវសៀវភៅគោលការណ៍ណែនាំ ស្តីពីការរៀបចំនិងការអនុវត្តថវិកា MoSVY-FMM ដើម្បីធានាបាននូវតម្លាភាពនិងប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រសួងស.អ.យ.
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស ដើម្បីកៀរគរធនធានបម្រើឱ្យតម្រូវការ និងសំណូមពររបស់ជនរងគ្រោះនិងងាយរងគ្រោះគ្រប់ប្រភេទ និងពង្រឹងពង្រីកទំនាក់ទំនងសហប្រតិបត្តិការទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសនានា ក្នុងតំបន់អាស៊ាន និងសាកលលោក
- ពង្រឹងការងារអធិការកិច្ច ដោយប្រមូលផ្តុំលើ ការធ្វើអធិការកិច្ច អង្គភាព មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត លើការអនុវត្តបទបញ្ជាផ្ទៃក្នុង របៀបរបបការងារ និងការគ្រប់គ្រងវត្តមានរបស់មន្ត្រី និងការដោះស្រាយបណ្តឹងនិងវិវាទការងារជូនមន្ត្រីរាជការរបស់ក្រសួងប្រកបដោយយុត្តិធម៌

- បន្តធ្វើសវនកម្មនៅតាមអង្គភាព និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្តលើការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋ។

**ការអភិវឌ្ឍធនធានមនុស្ស**

- បណ្តុះបណ្តាលវិជ្ជាជីវៈកម្រិតឧត្តមសិក្សា និងកម្រិតវិញ្ញាបនបត្រ ដោយប្រមូលផ្តុំលើ ការបណ្តុះបណ្តាលវិជ្ជាជីវៈកម្រិត ថ្នាក់បរិញ្ញាបត្រ សង្គមកិច្ច សង្គមវិទ្យា កិច្ចគាំពារសង្គម គ្រប់គ្រងសាធារណៈ រដ្ឋបាលសាធារណៈ គោលនយោបាយសង្គម គោលនយោបាយសាធារណៈ អក្សរសាស្ត្រអង់គ្លេស និងបរិញ្ញាបត្រវិស្វកម្មឧបករណ៍សិប្បនិម្មិតនិងរណប និងការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈជំនាញសង្គមកិច្ច ទៅតាមកម្មវិធីសិក្សាកម្រិត១ដល់កម្រិត៤ និងការបណ្តុះបណ្តាលរយៈពេលខ្លីកម្រិតវិញ្ញាបនបត្រលើមុខជំនាញផ្សេងៗ
- ពង្រឹង និងពង្រីកសមត្ថភាពវិទ្យាស្ថានជាតិសង្គមកិច្ច ដោយប្រមូលផ្តុំលើ ការជ្រើសរើសគ្រូបង្រៀនដែលមានសមត្ថភាព ការរៀបចំផែនការបណ្តុះបណ្តាល ការអភិវឌ្ឍកម្មវិធីសិក្សា ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងការបំពាក់បរិក្ខារសិក្សាសមរម្យ៕

ថ្ងៃ ១៤ ១០ ៣ ខែ ម្រិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ វិច្ឆិកា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**វង សូត**

## តារាង

## ចំណុចដៅនៃសូចនាករសំខាន់ៗ

## របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

| ល.រ | សូចនាករ | ឯកតា | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ |
|---|---|---|---|---|---|---|---|
| ១ | គ្រួសាររងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះមហន្តរាយ នៅតាមសហគមន៍ បានទទួលជំនួយសង្គ្រោះបន្ទាន់ | គ្រួសារ | ៧០ ២៤៣ | ៧១ ៦៤៨ | ៥៧ ៤០២ | ៥៦ ២៥៤ | ៥៥ ១២៩ |
| ២ | ជនអនាថាដែលបានធ្វើសមាហរណកម្មទៅសហគមន៍វិញ | នាក់ | ៥៩៥ | ៥០៦ | ៤៣០ | ៣៦៦ | ៣១១ |
| ៣ | ជនអនាថាដែលទទួលបានសេវាគាំពារ | នាក់ | ៣ ២៦៦ | ៣ ៤៩៩ | ៣ ៧៣២ | ៣ ៩៦៥ | ៤ ១៩៨ |
| ៤ | ជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារផ្ទុកមេរោគអេដស៍ជំងឺអេដស៍ដែលទទួលសេវាថែទាំគាំទ្រតាមសហគមន៍ | នាក់ | ២ ៣៨៩ | ២ ៥០៨ | ២ ៦៣៣ | ២ ៧៦៥ | ២ ៩០៣ |
| ៥ | ជនវិបល្លាសស្មារតីទទួលបានសេវាព្យាបាល និងថែទាំ ក្នុងមជ្ឈមណ្ឌល | នាក់ | ១៤៦ | ១៦១ | ១៧៧ | ១៩៥ | ២១៥ |
| ៦ | ស្ត្រីមានផ្ទៃពោះនៅក្នុងគ្រួសារក្រីក្រទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ | នាក់ | ៥៩ ១៧៤ | ៦១ ០០៨ | ៦២ ៩០០ | ៧២ ៣៣៥ | ៨៣ ១៨៥ |
| ៧ | កុមារអាយុ ០-២ឆ្នាំ នៅក្នុងគ្រួសារក្រីក្រទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ | នាក់ | ១០៦ ២១២ | ១០៩ ៥០៥ | ១១២ ៨៩៩ | ១២៩ ៨៣៣ | ១៤៩ ៣០៨ |
| ៨ | ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ រំលោភបំពានផ្លូវភេទ ទទួលបានការស្តារនីតិសម្បទា | នាក់ | ៣០០ | ៣០០ | ៥០០ | ៥០០ | ៥០០ |
| ៩ | ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដែលត្រូវបានគាំពារ និងជួយសង្គ្រោះ | នាក់ | ២២០ | ២២០ | ២៥០ | ២៥០ | ២៥០ |
| ១០ | ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានធ្វើមាតុភូមិនិវត្តន៍ទៅប្រទេសខ្លួនវិញ | នាក់ | ២៥ | ២៥ | ៣០ | ៣០ | ៣០ |
| ១១ | ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានធ្វើមាតុភូមិនិវត្តន៍ពីក្រៅប្រទេស | នាក់ | ៣៥០ | ៣៥០ | ៣៩០ | ៣៩០ | ៣៩០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១២ | ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវទទួលបានការធ្វើសមាហរណកម្មទៅតាមសហគមន៍វិញ | នាក់ | ២៥០ | ២៥០ | ៣៥០ | ៣៥០ | ៣៥០ |
| ១៣ | ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានផ្តល់នូវសេវាក្រោយធ្វើសមាហរណកម្ម | នាក់ | ២០០ | ២០០ | ៤០០ | ៤០០ | ៤០០ |
| ១៤ | ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានបិទករណី | នាក់ | ១៥០ | ១៥០ | ១៥០ | ១៥០ | ១៥០ |
| ១៥ | កុមារកំព្រា និងកុមារងាយរងគ្រោះដែលរស់នៅក្នុងមណ្ឌលថែទាំកុមារ | នាក់ | ៥ ១៦៨ | ៤ ៩១០ | ៤ ៦៦៤ | ៤ ៤៣១ | ៤ ២០៩ |
| ១៦ | កុមារកំព្រា និងកុមារងាយរងគ្រោះដែលបានធ្វើសមាហរណកម្មទៅសហគមន៍វិញ | នាក់ | ១ ៧៣៦ | ២ ០៨៤ | ២ ៥០០ | ៣ ០០០ | ៣ ៦០១ |
| ១៧ | កុមាររងគ្រោះដែលទទួលបានការថែទាំដោយក្រុមគ្រួសារ និងសហគមន៍ | នាក់ | ២ ២៩៥ | ២ ៤១០ | ២ ៥៣១ | ២ ៦៥៧ | ២ ៧៩០ |
| ១៨ | កុមារដែលត្រូវបានសុំកូនអន្តរប្រទេស | នាក់ | ០០ | ០០ | ៥ | ៥ | ៥ |
| ១៩ | ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលទទួលបានការអនុញ្ញាតធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស | ទីភ្នាក់ងារ | ៣ | ៣ | ២ | ២ | ២ |
| ២០ | អត្រាអនីតិជនប្រព្រឹត្តល្មើសច្បាប់ដែលជាប់ក្នុងពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែ និងមណ្ឌលយុវនីតិសម្បទាទទួលបានសេវាស្តារនីតិសម្បទា | នាក់ | ១ ៥០០ | ១ ៤០០ | ១ ៤០០ | ១ ៤០០ | ១ ៤០០ |
| ២១ | កូនតាមម្តាយដែលមានអាយុចាប់ពី៣ (បី) ឆ្នាំឡើងទៅ នៅក្នុងពន្ធនាគារ ត្រូវបានទទួលសេវាសង្គមកិច្ច | នាក់ | ០៨ | ០៨ | ០៨ | ០៨ | ០៨ |
| ២២ | ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនបានស្តារនីតិសម្បទា | នាក់ | ៣ ៥៤២ | ៣ ៧៥០ | ៣ ៧០០ | ៣៧០០ | ៣៧០០ |
| ២៣ | ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនបានធ្វើសមាហរណកម្មទៅសហគមន៍វិញ | នាក់ | ១ ៦៩៤ | ១ ៩០០ | ១ ៩០០ | ១ ៩០០ | ១ ៩០០ |
| ២៤ | ជនពិការដែលទទួលបានសេវាស្តារលទ្ធភាពពលកម្មកាយសម្បទានៅតាមមជ្ឈមណ្ឌល | នាក់ | ២៨ ០០០ | ២៨ ០០០ | ២៨ ០០០ | ២៨ ០០០ | ២៨ ០០០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២៥ | ជនពិការដែលទទួលបានសេវាស្តារលទ្ធភាពពលកម្មនៅសហគមន៍ | នាក់ | ៩ ០០០ | ៩ ០០០ | ៩ ០០០ | ៩ ០០០ | ៩ ០០០ |
| ២៦ | ជនពិការក្រីក្រទទួលបានរបបគោលនយោបាយឧបត្ថម្ភសេវាស្តារនិងពិនិត្យថែទាំសុខភាព | នាក់ | ៩ ០០០ | ៩ ០០០ | ៩ ០០០ | ៩ ០០០ | ៩ ០០០ |
| ២៧ | ជនពិការទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ | នាក់ | ១០០ | ១០០ | ១២០ | ១២០ | ១៤០ |
| ២៨ | ជនពិការត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារនៅតាមស្ថាប័នរដ្ឋ(២%) | នាក់ | ៣ ១២១ | ៣ ១៥១ | ៣ ១៨១ | ៣ ២១១ | ៣២៤១ |
| ២៩ | ជនពិការត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារនៅតាមស្ថាប័នឯកជន (១%) | នាក់ | ៣ ៥០០ | ៣ ៥០០ | ៣ ៥០០ | ៣ ៥០០ | ៣ ៥០០ |
| ៣០ | ជនពិការក្រីក្រនៅតាមសហគមន៍ទទួលបានរបបឧបត្ថម្ភគោលនយោបាយ | នាក់ | ១៩ ២២៨ | ២២ ២២៨ | ២៥ ២២៨ | ២៨ ២២៨ | ៣១ ២២៨ |
| ៣១ | ជនពិការទទួលបានសេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ | នាក់ | ៥៥ ០០០ | ៥៥ ០០០ | ៥៥ ០០០ | ៥៥ ០០០ | ៥៥ ០០០ |
| ៣២ | អត្រាមនុស្សចាស់ក្រីក្រគ្មានទីពឹងទទួលបានសេវាថែទាំនៅតាមសហគមន៍ | % | ៥ | ៦ | - | - | - |
| ៣៣ | មនុស្សចាស់ក្រីក្រគ្មានទីពឹងទទួលបានសេវាថែទាំក្នុងមជ្ឈមណ្ឌលគាំពារមនុស្សចាស់ | នាក់ | ១០០ | ១៣០ | ១៣០ | ១៣០ | ១៣០ |
| ៣៤ | មនុស្សចាស់ក្រីក្រគ្មានទីពឹងទទួលបានគោលរបបគាំពារសង្គម | នាក់ | ៣៣៨ ០៧៦ | ៣៤០ ០០០ | ៣៤២ ០០០ | ៣៤៤ ០០០ | ៣៤៦ ០០០ |
| ៣៥ | និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុកដែលទទួលរបបសន្តិសុខសង្គម | នាក់ | ១០៧ ៨៩០ | ១០៩ ៦៤៥ | ១១២ ០៣០ | ១១៥ ០០៩ | ១១៨ ០២៣ |
| | និវត្តជនដែលទទួលរបបសោធន | នាក់ | ៥៧ ៤៤០ | ៥៨ ៣៣៩ | ៥៩ ៣៨៥ | ៦០ ៩៣៧ | ៦៣ ៥២២ |
| | ជនបាត់បង់សម្បទាវិជ្ជាជីវៈដែលទទួលរបបសោធន | នាក់ | ១ ៧១៩ | ១ ៥៩៩ | ១ ៤៤៣ | ១ ៣៣៨ | ១ ២៤០ |
| | អ្នកនៅក្នុងបន្ទុក | នាក់ | ៤៨ ៧៣១ | ៤៩ ៧០៧ | ៥១ ១៩៨ | ៥២ ៧៣៤ | ៥៣ ២៦១ |
| ៣៦ | អតីតយុទ្ធជនដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ១០៤ ៩៤៤ | ១០៨ ៤២៦ | ១១២ ១២៧ | ១១៦ ០៦១ | ១២០ ២៤៤ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | និវត្តជនដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ៣៨ ៤០៣ | ៤១ ១៨៧ | ៤៤ ១៧២ | ៤៧ ៣៧៤ | ៥០ ៨០៨ |
| | ជនបាត់បង់សមត្ថភាពការងារដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ១ ៤៨១ | ១ ៤៧២ | ១ ៤៦៣ | ១ ៤៥៥ | ១ ៤៤៦ |
| | ជនពិការដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ២៨ ៩១០ | ២៩ ២០៦ | ២៩ ៥០៥ | ២៩ ៨០៧ | ៣០ ១១២ |
| | ជនពលីដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ២៦ ៨៦១ | ២៦ ៩២០ | ២៦ ៩៨០ | ២៧ ០៣៩ | ២៧ ០៩៩ |
| | ជនមរណៈដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ៩ ២៨៨ | ៩ ៦៤១ | ១០ ០០៦ | ១០ ៣៨៦ | ១០ ៧៨០ |
| | អ្នកនៅក្នុងបន្ទុក | នាក់ | ១៥០ ៩៦៣ | ១៥៣ ៤៩៥ | ១៥៦ ០៦៩ | ១៥៨ ៦៨៧ | ១៦១ ៣៤៨ |
| ៣៧ | និស្សិតដែលបានចុះឈ្មោះចូលរៀនឆ្នាំទី១ | នាក់ | ២០០ | ២០០ | ២៥០ | ២៥០ | ២៥០ |
| ៣៨ | និស្សិតដែលកំពុងសិក្សាកម្រិតបរិញ្ញាបត្រ | នាក់ | ៥៥០ | ៥៥០ | ៦០០ | ៦៥០ | ៧០០ |
| ៣៩ | និស្សិតដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ | នាក់ | ៩៩ | ១២៩ | ២០០ | ២០០ | ២០០ |
| ៤០ | សិក្ខាកាមដែលបានបញ្ចប់ការសិក្សាកម្រិតវិញ្ញាបនបត្រ | នាក់ | ២៥០ | ២៥០ | ៣០០ | ៣០០ | ៣០០ |